សារព័ត៌មាន

# ខ្មែរម្ចាស់ស្រុក

Khmer Machas Srok News


សារព័ត៌មានចេញផ្សាយប្រចាំថ្ងៃ

ឆ្នាំទី ០៣ លេខ ៥៥២ ចេញផ្សាយថ្ងៃ សុក្រ ទី ១១ ខែ ធ្នូ ឆ្នាំ ២០០៩


## ករណីគប់គ្រាប់បែកប៉ះសម្លាប់ សម រង្ស៊ី កាលពី១២ឆ្នាំមុនត្រូវលាតត្រដាងដោយ FBI



លោក សម រង្ស៊ី និងលោកជា វិជ្ជា ក្រោយពេលទាយប្រហារដោយគ្រាប់បែកឆ្លាមៗ



ជនរងគ្រោះដោយសារគ្រាប់បែកថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៧

កាសែតស្តង់ដារអន្តរជាតិ ២ ភាសា គឺភាសាខ្មែរ និងអង់គ្លេស បានលាតត្រដាថ្មីឡើងវិញនូវរឿងរ៉ាវនៃការវាយប្រហារដោយគ្រាប់បែកដៃ កាលពី១២ឆ្នាំមុន ធ្វើឱ្យជនកម្ពុជាស្លាប់យ៉ាងតិច ១៦នាក់ និងរបួសជាង១០០នាក់ ។

នៅថ្ងៃទី១០ ធ្នូ ២០០៩ The Cambodia Daily បានចុះផ្សាយអត្ថបទដែលពាក់ព័ន្ធនឹងរឿងនេះ ដោយដាក់ ចំណងជើងថា "*FBI*

តទៅទំព័រទី៤ ន

## លោកស្រីមូរសុខហួរប្រាប់សន្និសីទកំពូលស្ត្រីពិភពលោកអំពីអំពើហិង្សាលើស្ត្រីនៅកម្ពុជា



លោកស្រី មូរ សុខហួរ



ស្ត្រីខ្មែររងគ្រោះដោយអំពើហិង្សាពីសំណាក់អ្នកមានអំណាច

ដោយ : យុត្ត ពន្យ

សមាជិកាសភានៃគណបក្សសមរង្ស៊ីលោកស្រី *មូរ សុខហួរ* ដែលបានក្លាយទៅជាជនរងគ្រោះមួយរូបក្រោមសម្ពាធនយោបាយ ព្រោះតែហ៊ានចេញមុខតតាំងខាងផ្លូវច្បាប់ជាមួយនាយករដ្ឋមន្ត្រី *ហ៊ុន សែន* ដើម្បីអ្វី

តទៅទំព័រទី២ ស

## លោក សម រង្ស៊ី ថ្កោលទោសការមិនគោរពសិទ្ធិមនុស្សនៅកម្ពុជា



លោកហុរវ៉ាន់អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីដែលត្រូវគេដកហូតអភ័យឯកសិទ្ធិ



អ្នកតំណាងរាស្ត្រដែលធ្វើពហិការពេលសភាគណបក្សប្រជាជនដកអភ័យឯកសិទ្ធិសមរង្ស៊ី

ដោយ : គ.អរពិន្ទ

សម្រាប់ការចូលរួមជាមួយពិភពលោកក្នុងទិវាសិទ្ធិមនុស្សពិភពលោកលើកទី៦១ ដែលមនុស្សលោកនៃប្រទេសលទ្ធិប្រជាធិបតេយ្យទាំងឡាយសម្តែងអំណរសាទរនូវការមានសិទ្ធិសេរីភាពរបស់ខ្លួន ក្នុងពេលដែលពលរដ្ឋនៅកម្ពុជាជាប្រទេសមានបញ្ហាសិទ្ធិមនុស្សនោះ លោក *សម រង្ស៊ី* មេដឹកនាំនៃ

តទៅទំព័រទី២ ជ

## គណបក្សសមរង្ស៊ីអំពាវនាវឱ្យរដ្ឋាភិបាលក្លាហានទទួលស្គាល់ការរំលោភសិទ្ធិមនុស្សនៅកម្ពុជា



ប្រជាពលរដ្ឋខ្មែរនៅតែរងគ្រោះដោយការបណ្តេញចេញពីលំនៅដ្ឋាន

ដោយ : ជ័យ តារា

ខួបលើកទី៦១ នៃទិវាសិទ្ធិមនុស្សអន្តរជាតិ នៅក្នុងឆ្នាំនេះ គណបក្សសម រង្ស៊ី បានចេញសេចក្តីថ្លែងការណ៍មួយ ពិពណ៌នា អំពីសកម្មភាព រំលោភសិទ្ធិមនុស្សនៅកម្ពុជា ។ ជាមួយគ្នានោះដែរ គណបក្សសម រង្ស៊ី ក៏

តទៅទំព័រទី២ គ

## សង្គមស៊ីវិលរៀបចំទិវាសិទ្ធិមនុស្សអន្តរជាតិលើកទី៦១ដោយគ្មានការរំខានពីអាជ្ញាធរ



លោក ធន សារ៉ាយ



លោក អាត់ ធន់



លោក Christoph Peschoux



លោក Rafael Dochao Moreno



ក្មេងចូលរួមទិវាសិទ្ធិមនុស្សពិភពលោកលើកទី៦១ កាលពីម្សិលមិញ



គណៈអធិបតីពេលទស្សនារបាំជនជាតិភាគតិច

ដោយ : ចរិយា

នៅព្រឹកថ្ងៃទី១០ខែធ្នូ ២០០៩ អង្គការក្រៅរដ្ឋាភិបាល ចំនួន១៨ បានប្រមូលផ្តុំគ្នាធ្វើខួបលើកទី៦១ នៃទិវាសិទ្ធិមនុស្សអន្តរជាតិ ។ ការប្រមូលផ្តុំគ្នា ដែលចាប់ផ្តើមពីមាត់ទន្លេក្រៅបរិវេណទីស្នាក់ការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហៅកាត់ថា CDC នោះបានដង្ហែជាក្បួនតាមមហាវិថីរណបមាត់ទន្លេ សំដៅមុខវត្តបទុមវត្តីដែលជាកន្លែង

តទៅទំព័រទី៣ ម


ក្រុមហ៊ុនសំណង់ ថៃ ឡាគី នំាចូល នំាចេញ

THAY-LAKY IMPORT EXPORT AND CONSTRUCTION Co.,Ltd

Tel: (012) 954 606, 011 527 767,

012 862 515, 012 734 083, 012 991883, 012 255 435

E-mail: thaylakycounstruction@yahoo.com

USA: 5663 CHERRY AVE LONG BEACH, CA90805

E-mail: tanvuthay@verizon.net



ប្រសិនបើលោកអ្នកមានចំណាប់អារម្មណ៍

ផ្សព្វផ្សាយពាណិជ្ជកម្ម

លើទំព័រសារព័ត៌មានខ្មែរម្ចាស់ស្រុក

សូមទាក់ទងមកកាន់

ទូរស័ព្ទ : 0236 900 107, 017 360 678

ទូរសារ : 023 987 411

E-mail : kmsnews@gmail.com

www.kmsdaily.blogspot.com


## គ្មានការជួបគ្នារវាងហ៊ុនសែននិងអាប់ភីស៊ីតនៅឡាវទេធ្វើឱ្យទំនាក់ទំនងការទូតជុំនជាប់ដដែល



នាយករដ្ឋមន្ត្រីសៀម និងនាយករដ្ឋមន្ត្រីខ្មែរកាលពីនៅលួងព្រះបាង

ដោយ : រចនា

នាយករដ្ឋមន្ត្រី នៃប្រទេសពីរ ដែលកំពុងមានជម្លោះ ជាមួយនឹងគ្នាដ៏តានតឹង ហើយធ្វើឱ្យទំនាក់ទំនងការទូត ធ្លាក់ដុនដាបទៅៗនោះ មិនបានជួបគ្នានៅឯពិធីសម្ពោធកីឡាស៊ីហ្គេមលើកទី២៥ នៅឯប្រទេសឡាវ

តទៅទំព័រទី៣ ខ

### *បរិយាយថ្ងៃនេះ*

## ម្ចាស់ជំនួយថា កសិករខ្មែរមួយគ្រួសារត្រូវការដី២ហិកតាទើបរស់ រដ្ឋាភិបាលថា ១ហិកតាគ្រប់គ្រាន់

ដោយ : មាឌ្យ ប្រាជ្ញា

វាដូចជាការបង្ហាញឱ្យដឹងនូវអ្វីជាគោលគំនិតនយោបាយ ក៏ដូចជាជំរៅផ្នត់គំនិតរបស់មេដឹកនាំកម្ពុជាបច្ចុប្បន្ន ចំពោះការរស់នៅរបស់ប្រជារាស្ត្រខ្មែរក្នុងប្រទេសកម្ពុជាដែលពលរដ្ឋប្រមាណជាង៨០ភាគរយ ឬជាង១០លាននាក់ជាកសិករពឹងពាក់លើដីធ្លី ហើយដែលកសិករ២៥ភាគរយគ្មាន

តទៅទំព័រទី៤ ក

តមកពីទំព័រទី១ ស

ដែលលោកស្រីពិពណ៌នាថា ការពារកិត្តិយសស្ត្រីនោះលោកស្រីបានមានប្រសាសន៍អំពីស្ថានភាពនៃអំពើហិង្សាកើតមានលើស្ត្រីនៅកម្ពុជា ក៏ដូចជាប្រទេសនានា នឹងជាការផ្តល់តម្លៃឱ្យស្ត្រីទាំងឡាយក្នុងសង្គមនីមួយៗ។

លោកស្រី *មូរ សុខហួរ* បានមានប្រសាសន៍យ៉ាងនេះថា "*អំពើហិង្សាលើស្ត្រី មិនមែនកើតមានតែនៅក្នុងគ្រួសារក្រីក្រដោយសារបញ្ហាជីវភាពនោះទេ ក៏ប៉ុន្តែនៅក្នុងគ្រួសារអ្នកមានធូរធារ អ្នកមានអំណាច ក៏កើតមានអំពើហិង្សាដែរ*"។លោកស្រីបានបន្តទៀតថា អ្វីដែលធ្វើឱ្យស្ថានការណ៍កាន់តែធ្ងន់នោះ គឺប្រព័ន្ធយុត្តិធមិតុលាការពុករលួយ ដែលធ្វើឱ្យជនរងគ្រោះរឹតតែរងគ្រោះ។

គឺជាស្ថានភាពដែលតាមប្រសាសន៍លោកស្រី*មូរសុខហួរ* ថា ជាការ "*បន្តវប្បធម៌និទណ្ឌភាព ដោយជនរងគ្រោះនៅតែជាអ្នករងគ្រោះ ឯជនដែលបានប្រព្រឹត្តល្មើសនៅតែរួចខ្លួន*"។

សម្រាប់ករណីនៃអំពើហិង្សាទៅលើស្ត្រីនៅកម្ពុជានោះ ការសិក្សារបស់អង្គការសង្គមស៊ីវិលដែលចេញជារបាយការណ៍ជាហូរហែបានកត់សម្គាល់ថា មិនមែនតែនៅក្នុងគ្រួសារប្រជារាស្ត្រក្រីក្រអ្នកតូចតាចនោះទេ ដែលកើតមានអំពើហិង្សាសូម្បីតែក្នុងគ្រួសាររបស់អ្នកធូរធារ និងអ្នកមានក៏កើតមានអំពើហិង្សានោះដែរ។

តើអំពើហិង្សាប្រព្រឹត្តទៅលើស្ត្រីកើតមានក្នុងករណីនៃស្ថានភាពនៅកម្ពុជាជាប្រទេសដែលបានឆ្លងកាត់សង្គ្រាមរបប មហាឧក្រិដ្ឋនៃក្រុម ប៉ុល ពត នួន ជា អៀង សារី ឬយ៉ាងណានោះ ? ចំពោះសំណួរនេះ លោកស្រី *មូរ សុខហួរ* បានអធិប្បាយថា "*ប្រទេសខ្លះមានកម្រិតអំពើហិង្សាលើកម្ពុជា*" ដោយលោកស្រីចង្អុលទៅរកប្រទេសដែលធ្លាប់បានឆ្លងកាត់របបកុម្មុយនីស្តដឹកនាំដោយគណបក្សតែមួយក្នុងអតីតសហភាពសូវៀត។

លោកស្រី *មូរ សុខហួរ* បានមានប្រសាសន៍ថាជាឧទាហរណ៍ប្រទេសក្នុងប្លុកអតីតសហភាពសូវៀត ដូចជាអ៊ុយក្រែន អាមេនី ជាប្រទេសដែលធ្លាប់បានឆ្លងកាត់របបកុម្មុយនីស្តដឹកនាំដោយគណបក្សតែមួយនោះនៅកើតមានអំពើហិង្សាលើស្ត្រីការជួញដូរស្ត្រីពីព្រោះតែស្ត្រីខ្វះការងារ ហើយជាស្ថានភាពធ្ងន់ធ្ងរ។

ឧទាហរណ៍មួយទៀតត្រូវបានលោកស្រីលើកយកមកបំភ្លឺក្នុងនាមជាសកម្មជនពិភពលោកម្នាក់និងជាអតីតរដ្ឋមន្ត្រីក្រសួងកិច្ចការនារីនៃរដ្ឋាភិបាលកម្ពុជាអាណត្តិទី២នោះគឺករណីប្រទេស រ៉ូវ៉ាន់ដា នៅទ្វីបអាហ្វ្រិក ជាប្រទេសដែលធ្លាប់បានឆ្លងកាត់សង្គ្រាម និងរបបប្រល័យពូជសាសន៍ដ៏សាហាវឃោរឃៅកាលក្នុងអំឡុងឆ្នាំ១៩៩៤។

លោកស្រី *មូរ សុខហួរ* បានមានប្រសាសន៍ថា "*ប្រទេសរ៉ូវ៉ាន់ដាបានឆ្លងកាត់អំពើប្រល័យពូជសាសន៍រយៈពេលខ្លី កំពុងក្លាយជាប្រទេសមានការគោរពសិទ្ធិមនុស្ស ហើយស្ត្រីសមាជិកសភាមានចំនួនដល់ទៅ៥៦ភាគរយ ។ ប្រធានសភាជាតិនៃប្រទេសរ៉ូវ៉ាន់ដាគឺជាស្ត្រី*"។ ដោយផ្អែកលើមូលដ្ឋាននេះ លោកស្រីបានអធិប្បាយថា ដូច្នេះបញ្ហា នៃអំពើហិង្សាកើតមាននៅក្នុងគ្រួសារ ការរំលោភសិទ្ធិមនុស្សក្តីនោះ គឺជាឆន្ទៈមេដឹកនាំរបស់ប្រទេសនីមួយៗដែលថា តើគ្រប់គ្រងប្រទេសរបស់ខ្លួនដោយប្រើច្បាប់ ឬមនុស្ស ?

ត្រង់ចំណុចនេះ លោកស្រីបានចង្អុលពីការគោរពច្បាប់ "*ការកែទម្រង់ស្ថាប័នរដ្ឋឱ្យឯករាជ្យ... ការបំបាត់អំពើពុករលួយ គំនិតបក្ខពួកនិយម ហើយដែលជំហរចេញពីប្រភព៣ និងវិធានការ៣ដែលដើរទន្ទឹមគ្នា*"។

ចុះថាតើចលនាស្ត្រីពិភពលោកដើរដល់តំណាក់កាលណាហើយនោះ? ត្រង់នេះលោកស្រី *មូរ សុខហួរ* បានថ្លែងថា "*ការប្រជុំស្ត្រីនៅសន្និសីទកំពូលអន្តរជាតិបង្ហាញថា ... កម្លាំងនយោបាយស្ត្រីក្នុងប្រទេសនីមួយៗពីថ្នាក់មូលដ្ឋាន ដល់ថ្នាក់ជាតិ*"។

ទន្ទឹមនឹងនេះដែរ លោកស្រី *មូរ សុខហួរ* បានថ្លែងបញ្ជាក់បន្ថែមថា "*យើងជាស្ត្រីអ្នកនយោបាយ ជាសមាជិកសភាគួរកុំភ្លេច ត្រូវហ៊ាននិយាយការពារស្ត្រីដែលរងការរំលោភ។ ចំពោះយើងសមាជិកសភាត្រូវបំពេញតួនាទីការពារស្ត្រី ទោះបីរដ្ឋាភិបាលដឹកនាំដោយគណបក្សរបស់ខ្លួន ក៏ត្រូវទាមទារឱ្យរដ្ឋាភិបាល ... រក្សាភាពថ្លៃថ្នូររបស់ស្ត្រីពិតប្រាកដ*"។

បញ្ហានៃការដកព្យួរអភ័យឯកសិទ្ធិសភារបស់លោកស្រី *មូរ សុខហួរ* សមាជិកសភាស្ត្រីពីគណបក្សសមរង្ស៊ី ក៏ដូចជាបណ្តឹងចោទប្រកាន់លោកស្រីដោយនាយករដ្ឋមន្ត្រី *ហ៊ុនសែន* តាមរយៈតុលាការដែលគេដឹងថាមិនឯករាជ្យ និងជាឧបករណ៍របស់គណបក្សប្រជាជននោះគឺជាចំណាប់អារម្មណ៍របស់ពិភពលោកទាំងនៅក្នុងជួរអ្នកនយោបាយជាន់ខ្ពស់ ក៏ដូចជាចលនាសកម្មជនសិទ្ធិស្ត្រីពិភពលោករាប់ទាំងសមាជិកសភាសហរដ្ឋអាមេរិក និងអឺរ៉ុប និងអង្គការស្ត្រីទាំងឡាយដែលធ្វើសកម្មភាពជាអន្តរជាតិផង។

ហើយនេះគឺជាតឹកតាងមួយដែលមិនអាចឱ្យរដ្ឋាភិបាលគណបក្សប្រជាជននៃលោក *ហ៊ុន សែន* អះអាងអ្វី ដើម្បីពន្យល់ថា មានការគោរពលើកតម្កើងតម្លៃស្ត្រី និងសិទ្ធិស្ត្រីនៅកម្ពុជានោះទេ បើត្រឹមតែលោកស្រី *មូរ សុខហួរ* ជាតំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា និងព្យាយាមទាមទារកិត្តិយសរបស់លោកស្រីប៉ះពាល់ដោយអ្វីដែលលោកស្រីអះអាងថា ជាការថ្លែងប្រមាថរបស់នាយករដ្ឋមន្ត្រីលោកស្រីបែរជារងនូវសម្ពាធគាបសង្កត់ថែមទៀតនោះ៕

តមកពីទំព័រទី១ ៩

គណបក្សប្រឆាំងដ៏ធំបំផុតនៅកម្ពុជាបានចេញសារលិខិតមួយពិពណ៌នាស្ថានភាពសិទ្ធិមនុស្សនៅក្នុងស្រុកខ្មែរ។

លោកសមាជិកសភាសម រង្ស៊ី ពីគណបក្សសមរង្ស៊ី ជាគណបក្សដៃគូរប្រជែងដ៏ធំតទល់នឹងគណបក្សកាន់អំណាច បានមានប្រសាសន៍នៅក្នុងលិខិតរបស់លោកអធិប្បាយថា នៅកម្ពុជាបច្ចុប្បន្ន ក្រោមការដឹកនាំប្រទេសដោយគណបក្សប្រជាជននោះ ពុំមានទេសិទ្ធិមនុស្ស ហើយក៏ពុំមានការគោរពសិទ្ធិមនុស្សជាសិទ្ធិរបស់ពលរដ្ឋទូទៅនោះដែរ។

លោកបានលើកយកឧទាហរណ៍ចំជាក់ស្តែងដែលជាការកត់សម្គាល់របស់សាធារណៈមតិក្នុងប្រទេស ក៏ដូចជាចំណាប់អារម្មណ៍របស់ពិភពលោកទាំងសមាជិកសភានៃប្រទេសមានឥទ្ធិពលមហាអំណាចធំៗ អំពីការដកព្យួរអភ័យឯកសិទ្ធិសភារបស់រូបលោកផ្ទាល់ ធ្វើឡើងដោយក្រុមសមាជិកសភានៃគណបក្សប្រជាជនកាលពីថ្ងៃទី១៦ ខែវិច្ឆិកា។

លោក *សម រង្ស៊ី* បានលើកឡើងថា នោះគឺជាវិធានការដែលកើតឡើងជាលើកទី២ក្នុងឆ្នាំ២០០៩នេះ ដែលតំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភាការពារដោយរដ្ឋធម្មនុញ្ញរបស់ប្រទេសពោលគឺសមាជិកសភាគណបក្សសមរង្ស៊ីដល់ទៅ៣រូប រាប់ទាំងរូបលោកផង បានរងការដកព្យួរអភ័យឯកសិទ្ធិសភាដោយគណបក្សកាន់អំណាច។

ហើយតែក្នុងអំឡុងចន្លោះពេល៥ខែប៉ុណ្ណោះ បន្ទាប់ពីសមាជិកសភាគណបក្សប្រជាជនបានប្រកាន់នូវអ្វីដែលលោក *សម រង្ស៊ី* ផ្ទាល់បានអធិប្បាយថាជាស្ថាប័នមិនឯករាជ្យហើយសម្រាប់តែបោះត្រាឱ្យគណបក្សប្រជាជន និងនាយករដ្ឋមន្ត្រី *ហ៊ុន សែន* ដកហូតព្យួរអភ័យឯកសិទ្ធិសភារបស់លោកស្រី *មូរ សុខហួរ* និងលោក *ហូរ វ៉ាន់* តំណាងរាស្ត្រពីររូបនៃគណបក្សសមរង្ស៊ីនោះ លោក *សម រង្ស៊ី* ក៏បានក្លាយទៅជាអ្នកនយោបាយកំពូលរបស់ជាតិទី៣ ដែលត្រូវគណបក្សប្រជាជនដកព្យួរអភ័យឯកសិទ្ធិសភាដែរ។

ហើយមាត្រាទី៨០ នៃរដ្ឋធម្មនុញ្ញ ក៏ត្រូវបានលោក *សម រង្ស៊ី* លើកយកមកបញ្ជាក់អំពីអភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្រទាំងអស់ ដែលជាតំណាងរាស្ត្រជាប់ឆ្នោតដោយការជ្រើសរើសរបស់រាស្ត្រខ្មែរ ដូច្នេះដូចមានចែងក្នុងរដ្ឋធម្មនុញ្ញជាច្បាប់កំពូលរបស់ជាតិទៀតនោះ ពុំមានមជ្ឈដ្ឋានទាំងឡាយណាមានអំណាចនឹងប្រព្រឹត្តអ្វីក្នុងការដកព្យួរអភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្ររបៀបនេះទេ។

ហើយករណីកាលដែលលោកជួបជាមួយម្ចាស់ដីស្រែនៅតំបន់ជាយដែនខេត្តស្វាយរៀងកាលពីថ្ងៃទី២៥ ខែតុលា បានដកចោលនូវបង្គោលបោះតម្រុយដោយគណៈកម្មាធិការព្រំដែននៃប្រទេសកម្ពុជា និងប្រទេសវៀតណាមកណ្តាលដីស្រែរបស់ប្រជាកសិករខ្មែរនោះ លោក *សម រង្ស៊ី* បានចង្អុលពន្យល់ដល់មាត្រាទី៤៤ នៃរដ្ឋធម្មនុញ្ញរបស់ប្រទេស។

លោកបានធ្វើការវែកញែកក្នុងនាមលោកជាតំណាងរាស្ត្រមួយរូបដែលក៏ជាតំណាងប្រជាជាតិកម្ពុជាមួយរូបផងដែរនោះថា ជនណាជាបុគ្គលក្តីជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។

ហើយដូច្នេះលោកមេដឹកនាំគណបក្សប្រឆាំងដែលកំពុងបន្តបេសកកម្មការទូតនៅតាមបណ្តាប្រទេសនានា ជាពិសេសនៅសហភាពអឺរ៉ុបនោះ បានលើកអធិប្បាយថា រូបលោកគឺជាតំណាងរបស់ប្រជារាស្ត្រ ជាតំណាងរាស្ត្រជាប់ឆ្នោត ហើយក៏ជាអ្នកនាំសាររបស់ប្រជារាស្ត្រខ្មែរនោះដែរអំពីអ្វីជាការចាប់អារម្មណ៍ ជាកង្វល់ ជាបញ្ហារបស់ប្រជារាស្ត្រម្ចាស់សន្លឹកឆ្នោត ក៏ដូចជារបស់ប្រទេសជាតិ។

លោក *សម រង្ស៊ី* បានថ្លែងបញ្ជាក់អំពីការដែលលោកស្រែកឱ្យកាន់តែឮខ្លាំង ប្រឆាំងថ្កោលទោសចំពោះការរំលោភលើសិទ្ធិសេរីភាពរបស់ប្រជារាស្ត្រហើយអស់ទាំងនោះក៏ព្រោះតែលោកចង់សម្តែងនូវការភ័យខ្លាចចំពោះអនាគតរបស់ប្រទេសកម្ពុជា។

តើប្រទេសកម្ពុជាមានអនាគតយ៉ាងណានោះបើការដឹកនាំប្រទេសប្រព្រឹត្តទៅតាមរបៀបបច្ចុប្បន្ន ដែលធ្វើឱ្យប្រជារាស្ត្រខ្មែរទូទៅ ជាម្ចាស់នគរមានកង្វល់បារម្ភ តាំងពីបញ្ហានៃការរំលោភយកដីធ្លីរបស់ប្រជាកសិករខ្មែរទៅប្រគល់ឱ្យក្រុមហ៊ុនឯកជនក្នុងស្រុក និងពីបរទេសរាប់ទាំងប្រគល់ឱ្យក្រុមហ៊ុនយួនផង ទាំងការបង្ក្រាបជិះជាន់ប្រជារាស្ត្របណ្តេញប្រជារាស្ត្រចេញពីដីធ្លី ទាំងអំពើពុករលួយទាំងអ្វីដែលលោក *សម រង្ស៊ី* និងគណបក្សរបស់លោក ក៏ដូចជាគណបក្សប្រឆាំងដទៃទៀតហៅថា ការបាត់បង់បូរណភាពទឹកដីកម្ពុជាដោយការទន្ទ្រានយករបស់ប្រទេសជិតខាងទាំងយួនទាំងលាវទាំងសៀមនោះ។

បញ្ហា នៃការបោះបង្គោលព្រំដែន ថ្មីបើជាបង្គោលតម្រុយក្តី ឬបង្គោលផ្លូវការក្តី អនុវត្តដោយគណៈកម្មាធិការព្រំដែនកម្ពុជាជាមួយសមភាគីគណកម្មាធិការព្រំដែនយួន តាមតំបន់បណ្តោយព្រំដែន ហើយដែលក៏មានការបញ្ចេញប្រតិកម្មខ្លាំងក្លា ដូចប្រជារាស្ត្រនៅភូមិកោះក្បានកណ្តាល ឃុំសំរោង ស្រុកចន្ទ្រា ខេត្តស្វាយរៀង តវ៉ានឹងការបោះបង្គោលទាំងមូលលើដីកសិករខ្មែរចំងាយច្រើនរយម៉ែត្រពីខ្សែព្រំដែនពីមុននោះ អស់ទាំងនេះ ពួកគាត់ជាសាក្សីរស់អាចយល់ច្បាស់ និងស្គាល់អំពីដំណើរនៃគ្រោះថ្នាក់របស់ប្រទេសកម្ពុជា ជាស្ថានភាពដូចការកត់សម្គាល់របស់ចលនាខ្មែរម្ចាស់ស្រុក ដែលកំពុងធ្វើយុទ្ធនាការយ៉ាងខ្លាំងលើឆាកអន្តរជាតិនោះ។

យ៉ាងណាក៏ដោយ ក៏ប្រជារាស្ត្រខ្មែរជាសាក្សីរស់នៅតំបន់ជាយដែន ដូចករណីនៅភូមិកោះក្បានកណ្តាល ឃុំសំរោង ស្រុកចន្ទ្រាខេត្តស្វាយរៀងនោះ ពួកគាត់ជាសាក្សីដ៏សំខាន់ដែលអធិប្បាយពន្យល់បានអំពីដំណើរនៃគ្រោះបាត់បង់ទឹកដីកម្ពុជា។ ប្រជាកសិករខ្មែរទាំងនោះបានអះអាងថាប្រឡាយយុទ្ធសាស្ត្រមួយត្រូវបានកម្ពុជាជីកក្នុងអំឡុងឆ្នាំ១៩៧៩ដើម្បីទប់ស្កាត់និន្នាការនៃការទន្ទ្រានរំកិលខ្សែព្រំដែន និងបង្គោលដោយយួនចូលមកក្នុងទឹកដីខ្មែរ។ ប៉ុន្តែការបោះបង្គោលតម្រុយសីម៉ាថ្មីធ្វើឡើងដោយគណៈកម្មាធិការលោក *វ៉ា គឹមហុង* និងគណកម្មាធិការយួននោះ ត្រូវប្រជារាស្ត្រអះអាងថា បានឆ្លងរំលងប្រឡាយយុទ្ធសាស្ត្រនោះមកទិសខាងលិចដោតដាំលើដីស្រែកសិករខ្មែរចំងាយដល់ទៅកន្លែងខ្លះ៣២០ម៉ែត្រពីខ្សែបន្ទាត់ព្រំដែនពីមុន។

ហើយសម្រាប់ទិវាសិទ្ធិមនុស្សពិភពលោក១០ធ្នូលើកទី៦១ កាលម្សិលមិញនោះ ការផ្សព្វផ្សាយអំពីស្មារតីខ្លឹមសារ និងអត្ថន័យ នៃពាក្យសិទ្ធិមនុស្ស ក៏បានលាន់ឮខ្ទរខ្ទារពាសពេញពិភពលោក ។មេដឹកនាំប្រទេសទាំងឡាយដែលមានជំហរស្មារតីស្គាល់និងយល់តម្លៃរបស់មនុស្សគ្រប់រូបស្មើគ្នា មិនថាអ្នកតូច អ្នកធំ អ្នកមាន អ្នកក្រ បានប្រកាន់យកនូវទស្សនៈជាក់ស្តែងថា មនុស្សកើតមកមានសិទ្ធិមនុស្សជាប់ខ្លួនដោយខ្លួនឯង។ ហើយសង្គមប្រកាន់តាមរបបគោលការណ៍ប្រជាធិបតេយ្យសេរី ដូចជាសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុបនោះ គោរពសិទ្ធិរហូតដល់មានការចុះផ្សាយទៀតថា ពាក្យថា ការរំលោភសិទ្ធិមនុស្ស មិនមែនសំដៅតែលើការជិះជាន់ធ្វើទុក្ខបុកម្នេញលើប្រជារាស្ត្រខាងរូបរៀងកាយនោះទេ។

អំពើស៊ីសំណូក ពុករលួយ ការកេងបន្លំថវិកាទ្រព្យសម្បត្តិជាតិក៏ត្រូវរាប់បញ្ចូលថាជាការរំលោភសិទ្ធិមនុស្សនោះផងដែរ ពីព្រោះគឺជាអ្វីដែលគេប្រើពាក្យជាភាសាអង់គ្លេសថា Betrayal of publec trust ប្រែមកថា "*ការក្បត់ទំនុកចិត្ត របស់សាធារណៈជន*"។

តាមអត្ថន័យ នៃពាក្យ "*សិទ្ធិមនុស្ស*" ជាសកលនេះ អ្វីៗដែលបាននឹងកំពុងកើតមាននៅកម្ពុជា ក្រោមការដឹកនាំរបស់រដ្ឋាភិបាលនោះ ចូលទៅក្នុងរបត់ដែលហៅថា ជាការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ដូចប្រតិកម្មកំពុងបន្តសម្តែងឡើងដោយសហគមន៍អន្តរជាតិ តាមរយៈការប្រជុំក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ក្រុងសឺណែវកាលដើមខែធ្នូនេះ ក៏ដូចជាសន្និសីទកំពូលស្ត្រីពិភពលោកស្តីអំពីបញ្ហា សិទ្ធិមនុស្សប្រារព្វឡើងនៅទីក្រុងសឺណែវថ្មីៗនេះផងដែរ៕

តមកពីទំព័រទី១ គ

បានអំពាវនាវ នៅក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួនកាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៩ ដោយស្នើឱ្យរដ្ឋាភិបាលមានសេចក្តីក្លាហាន ទទួលស្គាល់ការរំលោភសិទ្ធិមនុស្សនៅកម្ពុជា និងបញ្ហាជាច្រើនទៀត ដែលពលរដ្ឋខ្មែរទទួលរង នូវការរំលោភ សិទ្ធិមនុស្ស ។ សេចក្តីថ្លែងការណ៍នេះ មានខ្លឹមសារទាំងស្រុងដូចទៅ :

នៅពេលដែលប្រជាជាតិនៅលើពិភពលោកទាំងមូល ប្រារព្ធពិធីខួបលើកទី៦១ នៃទិវាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ នៅថ្ងៃទី១០ ខែធ្នូ ដើម្បីបញ្ជាក់ពីការទទួលស្គាល់ នូវសេចក្តីថ្លៃថ្នូររបស់មនុស្ស គ្រប់រូបថា ជាមូលដ្ឋាននៃយុត្តិធមិនិងសន្តិភាព លើសាកលលោកនោះ គណបក្សសម រង្ស៊ី សូមធ្វើការអំពាវនាវ ដល់រាជរដ្ឋាភិបាលបច្ចុប្បន្ន ដែលតំណាងព្រះរាជាណាចក្រកម្ពុជាជាហត្ថលេខីមួយ នៃសេចក្តីថ្លែងការណ៍ ជាសាកលស្តីពីសិទ្ធិមនុស្ស អោយមានការទទួលខុសត្រូវក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ឱ្យសមស្រប ត្រូវធានាឱ្យបាន នូវសេចក្តីថ្លៃថ្នូរ របស់ពលរដ្ឋខ្មែរដែលបាន នឹងកំពុងរងគ្រោះ ពីការរំលោភ នូវសិទ្ធិជាមូលដ្ឋានរបស់ខ្លួននោះ ។

ជំហានដំបូងគឺរាជរដ្ឋាភិបាលត្រូវមានសេចក្តីក្លាហានក្នុងការទទួលស្គាល់ នូវការរំលោភសិទ្ធិមនុស្សទាំងឡាយ ដែលកំពុងកើតមាន ដោយបង្កើត អោយមាននូវយន្តការ តាមដាន ការរំលោភសិទ្ធិមនុស្ស ថ្នាក់ជាតិមួយ ដែលឯករាជ្យ និងអព្យាក្រឹត ។ការស៊ើបអង្កេតលើការរំលោភសិទ្ធិមនុស្ស ដែលធ្វើឡើងដោយអង្គការ ដែលបានបង្កើតដោយរាជរដ្ឋាភិបាល ខ្លួនឯងបច្ចុប្បន្នមិនអាចជឿទុកចិត្តបានទេ ដរាបណាក្បាលម៉ាស៊ីនរបស់ គណៈកម្មាធិការ សិទ្ធិមនុស្សកម្ពុជា នៅតែត្រូវដឹកនាំដោយទីប្រឹក្សាលោកនាយករដ្ឋមន្ត្រីដែលបំពេញការងារសំរាប់តែធ្វើការ បិទបាំងនូវអំពើ នៃការរំលោភសិទ្ធិមនុស្សនោះ ។

ជាមួយនេះដែរគណៈកម្មការសិទ្ធិមនុស្សរបស់រដ្ឋសភា និងព្រឹទ្ធសភា ដែលដឹកនាំ និងចាត់ចែង ដោយគណបក្សប្រជាជនកម្ពុជានោះបានធ្វើឱ្យបាត់បង់នូវជំនឿទុកចិត្ត ចំពោះតួនាទី និងមុខងាររបស់ខ្លួន ដោយព្រោះតែមិនអាចការពារជនរងគ្រោះដោយសារតែការប្រព្រឹត្តល្មើសគឺចេញពីមនុស្ស ដែលជាមន្ត្រីមកពីគណបក្សរបស់ខ្លួននោះ។

សេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋយើង តម្រូវឱ្យមាន ជាចាំបាច់នូវការគោរពសិទ្ធិសេរីភាពរបស់ពលរដ្ឋខ្មែរ ឱ្យបានពេញលេញ ផ្តល់ការអប់រំឱ្យបានល្អប្រកបដោយគុណភាព និងការផ្តល់កិច្ចថែទាំសុខភាព អោយបានត្រឹមត្រូវ និងមិនយកថ្លៃ ។ ថវិកាជាតិឆ្នាំ២០១០ដែលគណបក្សក្នុងរាជរដ្ឋាភិបាលបានអនុម័តក្នុងពេលថ្មីៗនេះ បានឆ្លុះបញ្ចាំងឱ្យឃើញ កាន់តែច្បាស់ថែមទៀត ពីកង្វះឆន្ទៈ ក្នុងការលើកកំពស់សេចក្តីថ្លៃថ្នូរ របស់មនុស្ស ។ ការបង្កើតការយកពន្ធថ្មីទៀតពីប្រជាពលរដ្ឋយើងនៅពេលដែល មន្ត្រីរាជការស៊ីវិល និងយោធាយើង កំពុងតែជួបប្រទះ នឹងជីវភាពខ្វះខាតយ៉ាងខ្លាំង ហើយកម្មករ រោងចក្ររាប់ម៉ឺននាក់ បានបាត់បង់ការងារ តែរាជរដ្ឋាភិបាល មិនទាន់ចាត់វិធានការ ដោះស្រាយវិបត្តិសេដ្ឋកិច្ច ឱ្យបានត្រឹមត្រូវនោះផង ជាទង្វើដែលមិនអាចទទួលយកបាន ។

គណបក្សសម រង្ស៊ី សូមអំពាវនាវ ដល់មេដឹកនាំរាជរដ្ឋាភិបាលអោយបង្ហាញពីឆន្ទៈនយោបាយ និងសមត្ថភាពរបស់ខ្លួនក្នុងការដោះស្រាយ អំពើពុករលួយដ៏រីករាលដាល ដែលបានរារាំងពលរដ្ឋយើង មិនអោយទទួលបាន នូវសិទ្ធិក្នុងកិច្ចថែទាំសុខភាព សិទ្ធិទទួលបាន ការអប់រំ និងសិទ្ធិជាមូលដ្ឋាន ដទៃទៀត របស់មនុស្ស ដែលមានសារៈសំខាន់ ជាអាយុជីវិត សំរាប់ការអភិវឌ្ឍន៍ ពេញលេញ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស។

ការរំលោភបំពាន ដែកកំពុងរីករាលដាល ដោយទង្វើ របស់ក្រុមអ្នកមានអំណាច និងលុយកាក់ ដោយមានការចូលរួម ពីអាជ្ញាធរមូលដ្ឋាននិងកងកម្លាំងប្រដាប់អាវុធមួយចំនួន ហើយទទួលបានកិច្ចការពារ យ៉ាងពេញទំហឹងពីរាជរដ្ឋាភិបាល ធ្វើឱ្យសេចក្តីថ្លៃថ្នូរ និងសមត្ថភាពរបស់ប្រជាកសិករយើងពលរដ្ឋក្រីក្រនៅតាមជនបទនិងទីក្រុង រងទុក្ខវេទនា កាន់តែខ្លាំងឡើង ដោយសារការបាត់បង់ដីធ្លី និងផ្ទះសម្បែង និងបាត់បង់ សិទ្ធិមានលទ្ធភាពប្រកបការងារសំរាប់ទ្រទ្រង់ជីវភាពរបស់ខ្លួន ។

ការឈឺចាប់ ដោយអំពើ

តនៅទំព័រទី៣ គ

**តមកពីទំព័រទី១ ម**

បានរៀបចំទុកជាមុន ។

សមាជិកនៃអង្គការសិទ្ធិមនុស្សទាំង១៨ ដែលមានអាវ ពណ៌ស លឿងទុំ បៃតង ហើយពាក់មួកសរាប់ម៉ឺននាក់មកពីបណ្តាខេត្ត ក្រុងទូទាំងប្រទេស និងក៏មានជនជាតិភាគតិច មកពីខេត្តភាគឦសានផងនោះ បានដើរកាន់បដា សរសេរជាអក្សរខ្មែរពីលើ ហើយភាសាអង់គ្លេសនៅពីក្រោម ។ ខ្លឹមសារនៃបដាទាំងនោះ បញ្ជាក់ថា "*ការអភិវឌ្ឍន៍ ត្រូវបញ្ឈប់ ការរំលោភសិទ្ធិមនុស្ស,សិទ្ធិមនុស្សជាសិទ្ធិយើងទាំអស់គ្នា, យើងទាំងអស់គ្នាមានកាតព្វកិច្ច លើកស្ទួយក្នុងការ ការពារសិទ្ធិមនុស្សយើងទាំងអស់គ្នាត្រូវការសេរីភាព និងយុត្តិធម៌...*" ។

ពិធីដែលមានការចូលរួម ពីតំណាង របស់អង្គការជាតិអន្តរជាតិ តំណាងសិទ្ធិនុស្ស អង្គការសហប្រជាជាតិនោះ គ្មានការរំខានពីអាជ្ញាធរទេ ។ ប៉ុន្តែកងកម្លាំងបង្ក្រាបបាតុកម្ម ដែលប្រដាប់ដោយដំបងឆក់ ខ្នោះដៃ អាវុធនៅជាប់ដៃនោះ បានដាក់ពង្រាយនៅច្រកសំខាន់ៗ និងកន្លែងដែលបាំង ភ្នែកមហាជននៃការដ្ឋានមួយ ទល់មុខនាយកដ្ឋានអង្គរក្សដែលគេជឿថានឹងធ្វើការទប់ស្កាត់ រាល់សកម្មភាពនៃសង្គមស៊ីវិលធ្វើប្រឆាំងនឹងបំរាមអាជ្ញាធរ ។

វាគ្មិនជាច្រើនរូប ដែលជាមេអង្គការក្រៅរដ្ឋាភិបាលធំៗ ដូចជាលោក *ធន់សារ៉ាយ* ប្រធានអង្គការការពារសិទ្ធិមនុស្សអាដហុក និងក៏ជាប្រធាន សម្របសម្រួលស្តីទីរបស់គណៈកម្មាធិការ ប្រព្រឹត្តិកម្ម អង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា, លោក Christoph Peschoux ប្រធានការិយាល័យនៃឧត្តមស្នងការ អង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជា, លោកRafaele Dochao Moreno ភារធារី គណៈកម្មការអឺរ៉ុបប្រចាំកម្ពុជា,លោក *អាក់ ធន់* ជាប្រធានសភាព ការងារកម្ពុជា, លោក Jean Froancois Desmazieres ឯកអគ្គរដ្ឋទូតបារាំង ប្រចាំកម្ពុជា, លោក*ឈិត សំអាត* នាយកប្រតិបត្តិអង្គការវេទិកា នៃអង្គការ មិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និងមន្ត្រីសង្គមស៊ីវិលមួយចំនួនទៀត ។

លោក*ធន សារ៉ាយ* បានថ្លែងបើកកម្មវិធីដោយផ្តោតសំខាន់ទៅលើសិទ្ធិសេរីភាព នៃការបញ្ចេញមតិ និងសិទ្ធិមនុស្សជាសាកល ។

លោក Christoph Peschoux បានមានប្រសាសន៍ ពាក់ព័ន្ធទៅនឹងការបណ្តេញប្រជាពលរដ្ឋ ពីលំនៅដ្ឋាន បញ្ហាបណ្តឹង របស់លោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* ដែលប្តឹងលោកស្រី *មូរ សុខហួរ* អ្នកតំណាងរាស្ត្រ គណបក្សសម រង្ស៊ី និងការកាត់ទោសលោក*មឿងសុន* ប្រធានមូលនិធិ ទ្រទ្រង់អរិយធម៌ខ្មែរ ដោយគ្រាន់តែបញ្ចេញមតិស្តីពីការព្រួយបារម្ភនឹងការតាំងភ្លើងហ្វាប្រាសាទអង្គរវត្ត ព្រមទាំងជនជាតិភាគតិចនៅតំបន់ភាគឦសានប្រទេស បាត់បង់ដីធ្លី ជារបស់ដូនតារាប់សតវត្សរ៍មកហើយ ។

លោក បានមានប្រសាសន៍ថា នៅខេត្តរតនគីរី ជនជាតិភាគតិច បាននិងកំពុងរស់នៅអស់រយៈពេលជាច្រើនសតវត្សមកហើយនៅលើដីធ្លីរបស់ខ្លួនប៉ុន្តែប៉ុន្មានឆ្នាំថ្មីៗនេះ ដោយសារដីធ្លី បានក្លាយជាប្រភពថ្មីមួយនៃទ្រព្យសម្បត្តិនោះ ទើបពួកគាត់ ត្រូវបានគេដកហូតសិទ្ធិលើដីធ្លីរបស់ខ្លួន ។ច្បាប់ភូមិបាលគួរការពារ សិទ្ធិពួកគាត់ លើដីធ្លីរបស់ពួកគាត់ផង តែនៅលើករណីជាច្រើន ច្បាប់នេះមិនត្រូវបានគេយកមកអនុវត្តន៍ឡើយ ហើយពីមួយថ្ងៃទៅមួយថ្ងៃ អ្នកមានផលប្រយោជន៍សេដ្ឋកិច្ចដ៏មានអំណាចបានប្លន់យកដីធ្លីរបស់អ្នកភូមិដែលជារឿយៗ មានការគាំទ្រពីអាជ្ញាធរ ។ ហេតុអ្វីបានកើតមានបញ្ហានេះ ? ពីព្រោះពួកគេ មិនមែនជាជនជាតិខ្មែរ ពួកគេត្រូវបានចាត់ ថាជាអ្នកគ្មានអារ្យធម៌ ពួកគេជាអ្នកក្រ មិនចេះនិយាយភាសាខ្មែរ មានរបៀបរបប រស់នៅខុសប្លែកពីគេ និងជាជនទន់ខ្សោយ ហើយដែលងាយនឹងរងគ្រោះ ។

លោក Christoph Peschoux បន្តថា សហគមន៍ក្រីក្រ ជាច្រើននៅភ្នំពេញ ត្រូវបានចាត់ទុកថាជា "*អ្នកតាំងលំនៅខុសច្បាប់*" "*អ្នកតាំងលំនៅ មិនរៀបរយ*" "*ពួកអនាធិបតេយ្យ*" នៅពេលដែលពួកគេមួយចំនួនធំ មានសិទ្ធិកម្មសិទ្ធិស្របច្បាប់លើដីនោះ ដែលគេរស់នៅតាមច្បាប់ភូមិបាល ។ ដោយប្រកាសពួកគេថា "*ខុសច្បាប់*" ធ្វើឱ្យមានការ មិនយកចិត្តទុកដាក់ថែមទៀត ដល់សិទ្ធិពួកគេ តាមច្បាប់ ។នេះគឺជាការប្រព្រឹត្តមួយដែលមានការរើសអើងដែលនាំឱ្យមានវិវាទ និងការបណ្តេញចេញ។ ប្រសិនបើអនុវត្តច្បាប់ ភូមិបាលបានត្រឹមត្រូវវិវាទដីធ្លីជាច្រើននឹងមិនកើតឡើងទេ ហើយអាចដោះស្រាយបាន ។ ជាការពិតណាស់ មានពួកឱកាសនិយម ដែលឆ្លៀតកេងប្រយោជន៍ ពីវិវាទដីធ្លីដើម្បីទទួលបានសំណងមិនត្រឹមត្រូវ ក៏ប៉ុន្តែពួកទាំងនេះ មិនមានចំនួនច្រើនទេមានតែការអនុវត្តន៍ច្បាប់ភូមិបាលឱ្យបានត្រឹមត្រូវទេ ទើបអាចបែងចែកថានរណា មានសិទ្ធិស្របច្បាប់ និងនរណាខ្លះមិនមានសិទ្ធិលើដីធ្លីរបស់ពួកគេ ។ សំរាប់គោលបំណងនេះ ច្បាប់ត្រូវយកមកអនុវត្តន៍ អោយបានស្មើភាពគ្នា ។

លោកបានបញ្ជាក់ថា : រឿងក្តីលោកជំទាវ *មូរ សុខហួរ* តុលាការបានសំរេច បដិសេធបណ្តឹង ស្តីពីបទបរិហារកេរ្តិ៍ របស់លោកជំទាវ ហើយទទួលយកនូវបណ្តឹង របស់សម្តេចនាយករដ្ឋមន្ត្រី ។តើនេះគឺជាសេចក្តីសំរេចមួយត្រឹមត្រូវឬក៏មានការរើសអើង ? សេរីភាពនៃការបញ្ចេញមតិ ត្រូវបានធានាការពារក្នុងរដ្ឋធម្មនុញ្ញ ហើយការអនុវត្តន៍សិទ្ធិនេះត្រូវធ្វើដោយសេរីតែក្នុងក្របខណ្ឌកំណត់មួយចំនួន ដូចជាមិនត្រូវរិះគន់ ជាសាធារណៈនូវគោលនយោបាយ របស់រដ្ឋាភិបាល ការអនុវត្តន៍ជាក់ស្តែង ឬក៏ឯកត្តបុគ្គលទាំងឡាយ លើបញ្ហា ជាក់លាក់ណាមួយ-ជាពិសេស បើការរិះគន់ទាំងឡាយណា ដែលមើលឃើញថាចេញមកពីសម្លេងនយោបាយប្រឆាំង ។

កាលពីប៉ុន្មានខែថ្មីៗនេះ យើងសង្កេតឃើញ ពីការធ្វើព្រហ្មទណ្ឌនីយកម្ម នៃការបញ្ចេញមតិ មួយចំនួន បុគ្គលមួយចំនួន បានសំដែងនូវទស្សនៈរបស់ខ្លួន ពីបញ្ហា ពុករលួយ នៃមន្ត្រីជាន់ខ្ពស់មួយចំនួន ការដាក់ភ្លើងបំភ្លឺ នៅអង្គរវត្ត ឬការអភិរក្សត្រីផ្សោត នៅតាមដងទន្លេមេគង្គជាដើម ។ ទាំងអស់នេះ គឺជាការបញ្ចេញមតិ ហើយមិនមែនជាបទល្មើសទេ ទោះបីជានៅពេលខ្លះ គំនិតទាំងនេះ ចេញមកពីសម្លេងប្រឆាំងក៏ដោយ ។

លោកបានបន្តទៀតថា រដ្ឋធម្មនុញ្ញបង្កើតរបបនយោបាយ ពហុនិយម ។ ភាពខុសគ្នាខាងគំនិតក្នុងបរិយាកាសនយោបាយ យោគយល់គ្នាមួយ មិនគួរដោះស្រាយតាមរយៈការគំរាមកំហែង ការបំភិតបំភ័យឬបណ្តឹងព្រហ្មទណ្ឌនោះទេតែតាមរយៈការជជែកពិភាក្សាទល់មុខគ្នាជាសាធារណៈ ។មធ្យោបាយដែលល្អបំផុត ដើម្បីតបតចំពោះការកុហក់ ឬមតិ ដែលមិនមានព័ត៌មានគ្រប់គ្រាន់ ព័ត៌មានក្លែង គឺត្រូវតបតដោយការផ្តល់ព័ត៌មានអង្គហេតុ និងការពិតតាមរយៈការពិភាក្សា ។

គំនិតផ្សេងៗគ្នា ក្នុងសារព័ត៌មាន អាចដោះស្រាយបាន តាមរយៈការឆ្លើយតប ត្រូវចុះផ្សាយក្នុងសារព័ត៌មាននោះ ឆ្លើយតបចំពោះការចោទប្រកាន់ ដោយផ្តល់ហេតុពិត និងទឡ្ហីករណ៍ ។ សច្ចភាពគឺជាអាវុធ ដែលល្អបំផុតប្រឆាំងតបនឹងការកុហក់ និងក្លែងបន្លំ ។ ដាក់នរណាម្នាក់ក្នុងពន្ធនាគារ ដោយសារតែគាត់ បញ្ចេញទស្សនៈដោយសន្តិវិធី ទោះបីជាទស្សនៈនោះ ត្រូវបានបញ្ចេញ សំរាប់ហេតុផល នយោបាយក៏ដោយ គឺជាអកប្បកិរិយាមួយ នៃភាពមិនយោគយល់ខាងនយោបាយ គឺវាផ្ទុយពីគោលការណ៍នីតិរដ្ឋ និងបំពានស្មារតីរដ្ឋធម្មនុញ្ញ ។

លោក Rafaele Dochao Moreno បានថ្លែងនៅក្នុងពិធីនោះថា "*យើងពេលនេះ កំពុងតែអង្គុយក្នុងសភាពពិតប្រាកដមួយ ខ្ញុំមកនេះ ក្នុងនាមជាគណៈប្រតិភូអឺរ៉ុប តំណាងអោយ២៧ប្រទេស ស្មើ ៥០០លាននាក់ ប្រជាជនអឺរ៉ុប ។ ខ្ញុំសូមជូនសារ ដល់លោកអ្នក ។ ពលរដ្ឋអឺរ៉ុប ក៏កំពុងអបអរសាទរសិទ្ធិមនុស្សនេះដែរ ។សិទ្ធិមនុស្សជាការកំណត់ ពីភាពយល់ច្បាប់របស់មនសិការយើង ។យើងត្រូវជឿជាក់ថា យើងមិនមែនឯកោតែម្នាក់ឯងទេគឺមានពលរដ្ឋសហគមន៍អឺរ៉ុបនៅជាមួយផងដែរ*" ។

លោកបានបន្តថា សហគមន៍អឺរ៉ុប ជាម្ចាស់ជំនួយ ផ្តល់ឱ្យកម្ពុជា ហើយជាសហប្រតិបត្តិការផងដែរ ផ្នែកសិទ្ធិមនុស្ស និងគប្បីបញ្ឈប់អំពើហិង្សាចំពោះស្ត្រី បញ្ហាដីធ្លីរបស់ជនជាតិភាគតិច ។

លោកបន្តថា វាដូចជាយើងជិះកង់ បើកាលណាយើងឈប់ធាក់ កង់ កង់នឹងដួលហើយសិទ្ធិមនុស្សក៏ដូចគ្នាដែរ យើងត្រូវបន្តរហូតកុំឈប់ ទើបយើងមានសិទ្ធិ ពេញលេញ ។

នៅក្នុងពិធីប្រារព្ធទិវា កាលពីព្រឹកម្សិលមិញនេះ ក្រុមការងារសង្គមស៊ីវិល ក៏បានចេញសេចក្តីថ្លែងការណ៍មួយដែរ ។

សេចក្តីថ្លែងការណ៍ បញ្ជាក់ថា សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ត្រូវបានអនុម័ត ដោយមហាសន្និបាត អង្គការសហប្រជាជាតិ កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ ១៩៤៨ ។ សេចក្តីប្រកាស ជាសាកលនេះ បានទទួលស្គាល់ នូវសិទ្ធិនិងសេរីភាពជាមូលដ្ឋានរបស់មនុស្សទាំងអស់ ទាំងស្ត្រីនិងបុរស នៅគ្រប់ទីកន្លែងទាំងអស់ នៅទូទាំងពិភពលោក ដោយមិនមានការរើសអើងអ្វីទាំងអស់ ។ ចាប់តាំងពីត្រូវបានអនុម័ត កាលពីឆ្នាំ ១៩៤៨រួចមក សេចក្តីប្រកាសជាសាកលនេះ ត្រូវបានចាត់ទុកថាជា "*បទដ្ឋានសាកលមួយ នៃសមិទ្ធផល របស់មនុស្សគ្រប់ប្រជាជាតិទាំងអស់*" ។

សេចក្តីសេចក្តីថ្លែងការណ៍ បានបញ្ជាក់ទៀតថា នៅក្នុងឱកាសទិវាសិទ្ធិមនុស្សលើកទី៦១នេះផងដែរលោកស្រីឧត្តមស្នងការ *ណាវី ភីឡេ* នៃការិយាល័យ ឧត្តមស្នងការសិទ្ធិមនុស្ស នៃអង្គការ សហប្រជាជាតិ បានមានប្រសាសន៍ថា គោលបំណង នៃការប្រារព្ធ ធ្វើទិវាសិទ្ធិមនុស្ស នៅឆ្នាំ២០០៩នេះ គឺ "*ដើម្បីលើកស្ទួយ អោយមានសង្គមដែលមិនមាន ការរើសអើង និងពិភពលោកមួយដែលមានការប្រព្រឹត្តដោយស្មើភាពគ្នា សម្រាប់ទាំងអស់គ្នា*" ។ដែលមានន័យថា មនុស្សទាំងអស់កើតមកមានសេរីភាព និងសមភាព ប្រកបដោយភាពថ្លៃថ្នូរ និងមានសិទ្ធិ ពេញលេញ ។ បើទោះបីជា នៅក្នុងសេចក្តីប្រកាសជាសាកល ស្តីពីសិទ្ធិមនុស្ស កាលពី៦០ឆ្នាំមុនបានបង្កើតឱ្យមានមូលដ្ឋាន ជាក់លាក់ជាច្បាប់សិទ្ធិមនុស្ស អន្តរជាតិក៏ដោយ ក៏ប៉ុន្តែសព្វថ្ងៃនេះ អំពើរំលោភសិទ្ធិមនុស្ស និងការរើសអើង ប្រឆាំងនឹងមនុស្ស រាប់លាននាក់ នៅក្នុងពិភពលោក នៅតែបន្តកើតមាន ដែលយើងទាំងអស់គ្នាចាំបាច់ ត្រូវតែតស៊ូពុះពារ ប្រយុទ្ធប្រឆាំងថែមទៀត ។

ដោយឡែក ព្រះរាជាណាចក្រកម្ពុជាយើងវិញ ក៏បានចែង និងទទួលស្គាល់ថា សេចក្តីប្រកាសជាសាកលនេះ គឺជាផ្នែកមួយ នៃច្បាប់ជាតិរបស់ខ្លួនជាក់ស្តែងត្រង់មាត្រា៣១ នៃរដ្ឋធម្មនុញ្ញ ចែង ថា "*ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងនៅក្នុងធម្មនុញ្ញ នៃអង្គការសហប្រជាជាតិសេចក្តីប្រកាសជាសាកល ស្តីពីសិទ្ធិមនុស្ស និងកាតិការសញ្ញា ព្រមទាំង អនុសញ្ញាទាំងឡាយ ទាក់ទងទៅនឹងសិទ្ធិមនុស្សសិទ្ធិនារីនិងសិទ្ធិកុមារ*" ៕

**តមកពីទំព័រទី១ ខ**

ដែលចាប់ផ្តើមកាលពីថ្ងៃទី៩ខែធ្នូ ឆ្នាំ២០០៩កន្លងទៅនេះទេ។

លោក*ហ៊ុន សែន* នាយករដ្ឋមន្ត្រីខ្មែរ និងលោក*អាប់ភីស៊ិត វាចាជីវ៉ា* នាយករដ្ឋមន្ត្រីសៀម ដែលមានវត្តមានជាមួយគ្នានៅឯប្រទេសឡាវនោះមិនបានជួបដូចដែលមានវត្តមានជាមួយគ្នានៅទីក្រុងតូក្យូ ប្រទេសជប៉ុន កាលពីដើមខែមុនដែរដែលធ្វើឱ្យចំណងការទូត នៃប្រទេសទាំងពីរធ្លាក់សំយុងចុះយ៉ាងខ្លាំង ។

លោក*អ៊ឹង ស៊ាន* រដ្ឋលេខាធិការ ក្រសួងការបរទេស ដែលអមដំណើរលោក*ហ៊ុនសែន*ទៅទេសឡាវហើយវិលត្រឡប់មកកម្ពុជាវិញកាលពីព្រឹកថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៩ ម្សិលមិញនេះ ក៏បានបញ្ជាក់ប្រាប់ក្រុមអ្នកសារព័ត៌មានដែរថា គ្មានការជួបគ្នាទេ រវាងលោក*ហ៊ុន សែន* ជាមួយលោក*អាប់ភីស៊ិត* ។

ក្រុមអ្នកកាសែត បានរង់ចាំការផ្តល់បទសម្ភាសន៍ ឬធ្វើសន្និសីទជាមួយលោក*ហ៊ុនសែន*នៅឯព្រលានយន្តហោះ អន្តរជាតិភ្នំពេញ ដោយសារតែពួកគេរំពឹងថាលោក*ហ៊ុន សែន* អាចនឹងនិយាយ រឿងតានតឹង ជាមួយសៀម ដូចដែលគាត់ ធ្លាប់បាននិយាយ កាលពីវិលត្រឡប់មកពីប្រទេសជប៉ុនកាលពីដើមខែវិច្ឆិកា ។

នាយករដ្ឋមន្ត្រីឡាវធ្លាប់បានបង្ហើប អំពីការធ្វើមេអណ្តើកក្នុងការសម្របសម្រួលគ្នារវាងកម្ពុជានិងសៀមដែលការលើកឡើងនូវសេណារីយ៉ូនេះ ក៏ត្រូវបានស្វាគមន៍ ដោយភាគីកម្ពុជាដែរ ប៉ុន្តែបដិសេធដោយលោក*អាប់ភីស៊ិត* ។ការបដិសេធនេះក៏បាន ធ្វើឱ្យលោក*ហ៊ុន សែន* ខឹងខ្លាំង ហើយបានិយាយ នៅក្នុងស្រុកពញាក្រែក ខេត្តកំពង់ចាម កាលពីដើមខែនេះ ដោយមិនទទួលយកជំនួយ របស់ភាគីសៀម នៃរដ្ឋាភិបាល លោក*អាប់ភីស៊ិត វាចាជីវ៉ា* និងលោក រដ្ឋមន្ត្រីក្រសួងការបរទេស នៃប្រទេសសៀម *កាស៊ិត ភិរម្យ៉ា* នោះដែរ ។

ក្នុងកិច្ចប្រជុំ គណៈរដ្ឋមន្ត្រីប្រចាំសប្តាហ៍ កាលពីថ្ងៃទី៤ខែធ្នូ ឆ្នាំ២០០៩កន្លងទៅនេះ ប្រមុខរដ្ឋាភិបាល*ហ៊ុន សែន* បាននិយាយ អំពីការចង់ស្តារទំនាក់ទំនងការទូត រវាងប្រទេសទាំងពីរឡើងវិញដោយដាក់លក្ខខណ្ឌទៅលោក*អាប់ភីស៊ិត* ថា បើសិនជាសៀមបញ្ជូនឯកអគ្គរាជទូតឱ្យមកធ្វើការនៅកម្ពុជាវិញ កម្ពុជា ក៏បញ្ជូនឯកអគ្គរាជទូតអោយទៅធ្វើការ នៅប្រទេសសៀមវិញដែរ,ហើយកម្ពុជានឹងរក្សាប្រាក់ជំនួយ និងប្រាក់កម្ចី ១.៤០០លានបាតប្រហែល៤២លានដុល្លារ សម្រាប់កសាងផ្លូវលេខ៦៨ ពីស្រុកក្រឡាញ់ខេត្តសៀមរាប ទៅអូរស្មាច់ ខេត្តឧត្តរមានជ័យឱ្យនៅដដែល ។

ទំនាក់ទំនងការទូត រវាងប្រទេសកម្ពុជានិងសៀមបានធ្លាក់ចុះយ៉ាងខ្លាំង ហើយបណ្តាលឱ្យអាជ្ញាធរសៀម បណ្តេញប្រជាពលរដ្ឋខ្មែរ ដែលឆ្លងដែន ទៅធ្វើការនៅស្រុកសៀម រាប់ពាន់ម៉ឺននាក់ បន្ទាប់ពីលោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* តែងតាំងលោក*ថាក់ស៊ីន*ជាទីប្រឹក្សាសេដ្ឋកិច្ចគាត់ និងជាទីប្រឹក្សារាជរដ្ឋាភិបាល។

លោក*កាស៊ិតភិរម្យ៉ា*បានធ្វើឱ្យលោក*ហ៊ុន សែន* ខឹងខ្លាំង និងថា ភាពតានតឹងចាប់ផ្តើមតាំងពីទាហាន ឈុតខ្មៅសៀមលើកទ័ពឈ្លានពានកម្ពុជាកាលពីថ្ងៃទី១៥ ខែកក្កដា ២០០៨ គឺមួយសប្តាហ៍ បន្ទាប់ពីកម្ពុជាបញ្ចូល ប្រាសាទព្រះវិហារខ្មែរជាបេតិកភ័ណ្ឌពិភពលោក ៕

**តមកពីទំព័រទី២ គ**

អយុត្តិធម៌របស់អ្នកស្រុក អ្នកភូមិយើង ជាមួយនឹងសេចក្តីក្លាហាន ក្នុងការប្រយុទ្ធ ដើម្បីការពារដីធ្លីជាឯកជនឬជាសហគមន៍របស់ខ្លួន នៅតែត្រូវរាជរដ្ឋាភិបាលបច្ចុប្បន្នធ្វើមិនដឹងមិនឮ ។ ការបណ្តេញប្រជាពលរដ្ឋចេញពីលំនៅដ្ឋានដោយបង្ខំ និងការរឹបអូសយកដីធ្លី ដោយបំពាននៅតែបន្ត។ មិនតែប៉ុណ្ណោះការចោទប្រកាន់មូលបង្កាច់លើជនរងគ្រោះ ជាម្ចាស់ដីស្រែ ចំការដើម្បីចាប់ទៅឃុំឃាំង និងការបន្តផ្តល់សម្បទានដីធ្លីតាមប្រព័ន្ធមួយដែលគ្មានតម្លាភាព គឺមិនអាចបញ្ចប់បាន នូវការរំលោភលើសិទ្ធិមនុស្សដ៏គួរឱ្យភ័យខ្លាចនាបច្ចុប្បន្ននេះបានទេ ។

នីតិរដ្ឋ និងការធានា អោយមានយុត្តិធម៌ស្មើភាពនៅចំពោះមុខច្បាប់ នៅក្នុងតុលាការមួយដែលឯករាជ្យ និងមានសមត្ថភាព និងការផ្តល់ក្តីសង្ឃឹមដល់ជនរងគ្រោះ ដោយអំពើអយុត្តិធម៌ ឱ្យបានរស់នៅក្នុងជីវភាពមួយដែលរួចចាកពីការជិះជាន់និងការធ្វើទុក្ខបុកម្នេញ ត្រូវតែជាចក្ខុវិស័យ ដែលអ្នកដឹកនាំត្រូវធ្វើឱ្យបាន ។ មានតែការជ្រើសរើស យកសង្គមយុត្តិធម៌និងលទ្ធិប្រជាធិបតេយ្យ ត្រឹមត្រូវប៉ុណ្ណោះទេទើបអាចប្រយុទ្ធប្រឆាំង នឹងអំណាចផ្តាច់ការដើម្បីការពារសិទ្ធិមនុស្សអោយពេញលេញបាន ៕

**តមកពីទំព័រទី៤ ន**

ដែលស្ថិត នៅក្រោយគេហដ្ឋានលោក*ហ៊ុនសែន*ជាទីដែលកម្លាំងយោធា គណបក្សប្រជាជន បានឈរជើង។

សាក្សីទី២ បានអះអាងនៅក្នុងឯកសាររបស់FBI ថាបានឮដោយចៃដន្យពីទាហានដែលពិភាក្សាគ្នាអំពីការវាយប្រហារនេះ និងបានបង្ហាញអត្តសញ្ញាណ ទាហានម្នាក់ក្នុងចំណោមទាហាន ទាំងនោះថាជាមនុស្សម្នាក់ ដែលត្រូវបានពណ៌នា នៅក្នុងគំនូរព្រាងរបស់ FBI អំពីអ្នកវាយប្រហារ ដែលជាប់សង្ស័យទាំងនោះ ។

ឯកសាររបស់ FBI នេះ បានលើកឡើងថា "*ការធ្វើសម្ភាសន៍ទាំងនេះ គឺមានសារៈសំខាន់ព្រោះវាស្របនឹងព័ត៌មាន ដែលត្រូវបានផ្តល់ដោយសាក្សី ចំពោះការវាយប្រហារនេះថា អ្នកគប់គ្រាប់បែកបានរត់ចូលវត្តបទុម ។ ទោះបីជា (អ្នករៀបរាប់ដែលគេបានកត់ត្រាទុកនោះ) មិនបានឃើញការវាយប្រហារនេះក៏ដោយ ក៏ពួកគេបានភ្ជាប់ការជាប់ពាក់ព័ន្ធ ដ៏សំខាន់ជាមួយក្រុមទាហាន នៅបន្ទាយគណបក្សប្រជាជនកម្ពុជាដែលស្ថិតនៅពីក្រោយវត្តនេះដែរ*" ។

ឯកសាររបស់ FBI លើកឡើងថា "*សាក្សីនានា បានរាយការណ៍ថា ពួកគេមើលលែងឃើញបុរសទាំង២នាក់នោះ ដែលរត់ចូលទៅក្នុងវត្តនេះ នៅពេលដែលក្រុមទាហាន បានយកអាវុធភ្ជង់និងគំរាមកំហែងពួកគេ ដោយបញ្ចប់ ការដេញតាមរបស់ពួកគេទៅ*" ។

សាក្សីទី១ ក្នុងចំណោមសាក្សីទាំង២នាក់ដែលចម្លើយរបស់គាត់ត្រូវបានដកស្រង់កាលពីថ្ងៃទី១៣ ខែឧសភានោះ បានប្រាប់ FBI ថា នៅព្រឹក នៃការវាយប្រហារនោះ គាត់បានឃើញ ទាហាន១០នាក់ដើរទៅទិសខាងកើត កាត់តាមវត្តទៅកាន់សួនច្បារនោះ ។ សាក្សីរូបនេះ "*ឃើញទាហានទាំងនោះជាញឹកញាប់ ពីព្រោះបន្ទាយរបស់ពួកគេ ស្ថិតនៅពីក្រោយ ជាប់នឹងវត្តនេះ ។ ទោះយ៉ាងណា គាត់មិនចាំថា ធ្លាប់បានឃើញទាហានទាំងនោះ បានស្លៀកពាក់ឯកសណ្ឋានយោធាមួកដែក និងកាន់កាំភ្លើងដូចដែលពួកគេស្លៀកពាក់នៅព្រឹកនោះទេ*" ។ នេះបើយោងតាមខ្សែអាត់ថតបទសម្ភាសន៍របស់FBI ។ "*ព្រឹកថ្ងៃទី៣០ មេខីមា ១៩៩៧ ពួកគេស្លៀកពាក់ សម្រាប់ការប្រយុទ្ធ ហើយទាហានម្នាក់ កាន់កាំភ្លើង២ដើម*" ។

យោងតាមឯកសាររបស់ FBI បានឱ្យដឹងថា សាក្សីរូបនេះ បាននិយាយថា គាត់កំពុងដេកនៅក្នុងកន្លែងរបស់គាត់ ស្រាប់តែគាត់ឮសម្លេងផ្ទុះចំនួន៤ដង ផ្ទួនៗគ្នា ។

"*ភ្លាមៗ បន្ទាប់ពីការផ្ទុះនោះ គាត់បានឃើញបុរស២នាក់ ដើរយ៉ាងលឿន កាត់បរិវេណវត្តនេះ ពីកើតទៅលិចឆ្ពោះទៅកាន់បន្ទាយទាហាន ។ បុរសទីមួយធ្វើសកម្មភាពយ៉ាងចម្លែក ដូចជាគាត់ជ្រួលច្របាលហើយគាត់ងាកក្រោយ ជាច្រើនដង នៅពេលដែលគាត់ដើរយ៉ាងលឿន ។ ទឹកមុខរបស់គាត់ស្លេកស្លាំង*" ។

បុរសនោះ គឺជាជនកម្ពុជាមានអាយុ២៧ឆ្នាំ ឬ២៨ឆ្នាំ និងមានកំពស់ ប្រហែល១,៦៨ម៉ែត្រ មានសម្បុរជ្រះ ពាក់អាវដៃវែង ពណ៌បៃតងចាស់ ពីលើអាវពណ៌ស ។

ឯកសាររបស់ FBI លើកឡើងថា "*គាត់បានមើលបុរសនេះ ដើរហួសកន្លែងរបស់គាត់ ហើយបន្តឆ្ពោះ ទៅបន្ទាយទាហាន នៅពីក្រោយវត្ត*" ។

**(តនៅលេខក្រោយ)**

**តមកពីទំព័រទី១ ន**

*បញ្ចេញឯកសារស៊ើបអង្កេត អំពីការគប់គ្រាប់បែកនៅឆ្នាំ១៩៩៧"* ដែលជាអត្ថបទភាសាខ្មែរ បកប្រែពីភាសាអង់គ្លេស ។

កាសែតសរសេរថា កំណត់ត្រាដែលត្រូវបាន ប្រកាសជាចំហដ៏ថ្មីស្រឡាង របស់ការិយាល័យស៊ើបអង្កេត សហព័ន្ធអាមេរិក (FBI) បង្ហាញថា ក្រុមអ្នកស៊ើបអង្កេតជឿជាក់កាលពីឆ្នាំ១៩៩៧ថា ពួកគេបានរកឃើញភស្តុតាងភ្ជាប់កងកម្លាំងសន្តិសុខដែលស្មោះត្រង់នឹងគណបក្សប្រជាជនកម្ពុជា ទៅនឹងការវាយប្រហារ ដោយគ្រាប់បែកដៃលើក្បួនដង្ហែរប្រឆាំងមួយ នៅទីក្រុងភ្នំពេញនាឆ្នាំនោះដែលបានសម្លាប់មនុស្ស អស់យ៉ាងហោចណាស់១៦នាក់ និងធ្វើឱ្យមនុស្សជាង១០០នាក់រងរបួស ។

ដោយបញ្ចេញមក ឱ្យកាសែត The Cambodia Daily ក្រោមច្បាប់សេរីភាព នៃសារព័ត៌មានឆ្នាំ១៩៦៦ ជាច្បាប់របស់អាមេរិក ដែលតម្រូវឱ្យមានការពិនិត្យ និងបង្ហាញ នូវកំណត់ត្រារបស់រដ្ឋាភិបាលតាមការស្នើនោះ ។ ឯកសារទាំងនេះបង្ហាញពីការប្រកាស ជាចំហ លើកទីមួយរបស់ FBI អំពីកំណត់ត្រាស៊ើបអង្កេតនានា ដែលទាក់ទង ទៅនឹងការវាយប្រហារកាលពីថ្ងៃ៣០មីនា១៩៩៧នោះ ។

យោងតាមឯកសារផ្ទៃក្នុងរបស់ FBI ដែលបានប្រកាសជាចំហនិងយោងតាម ប្រធានស៊ើបអង្កេតរបស់ FBI លើការវាយ ប្រហារនោះដែលបាននិយាយជាមួយThe Cambodia Daily នៅក្នុងការអធិប្បាយអំពីករណីនេះ ជាសាធារណៈនិងជាលើកដំបូងរបស់លោកបានអោយដឹងថា ដោយសារតែការគំរាមចំពោះសន្តិសុខរបស់ពួកគេ និងភាពតានតឹងនយោបាយជាច្រើននោះក្រុមអ្នកតំណាង របស់ FBI ដំបូងដែលត្រូវបានបញ្ជូន ឱ្យមកស៊ើបអង្កេតករណីវាយប្រហារនេះ ត្រូវបានហៅ ឱ្យត្រឡប់ទៅវិញ ខណៈដែលការងាររបស់ពួកគេបានឈានដល់ ដំណាក់កាលសំខាន់នៅក្នុងឆ្នាំនោះ ។

ដោយឥឡូវនេះបានចូលនិវត្តន៍ហើយនោះលោក*ថូម៉ាស់នីកូលែតទី* ជាភ្នាក់ងារពិសេស ដែលបានដឹកនាំការស៊ើបអង្កេតជាច្រើនរបស់ FBI នៅខាងក្រៅសហរដ្ឋអាមេរិកនៅក្នុងអាជីពរយៈពេល២៤ឆ្នាំរបស់លោក ជាមួយការិយាល័យស៊ើបអង្កេតនេះមានប្រសាសន៍ថាភស្តុតាងដែលភ្ជាប់កងកម្លាំងដែលស្មោះត្រង់ ជាមួយនឹងគណបក្សប្រជាជននោះគឺ " *ច្រើន* " ក៏ប៉ុន្តែមិនទាន់ពេញលេញ ។

លោក*នីកូលែតទី*ក៏បានបញ្ជាក់អះអាងផងដែរ អំពីការរកឃើញជាលើកដំបូង ក្នុងឯកសាររបស់ FBI ដែលទំនងជាបង្ហាញថា មានការដឹងជាមុន ពីសំណាក់នគរបាលកម្ពុជា អំពីការវាយប្រហារដោយគ្រាប់បែកដៃនៅកន្លែងកើតហេតុនោះ ហើយក្រោយមកមានការសហការគ្នា ជាមួយមនុស្ស ដែលគេចោទថា ជាជនដៃដល់ដែលរត់គេចខ្លួនពីសំណាក់ក្រុមសមាជិកអង្គភាពនៃអង្គរក្សផ្ទាល់ខ្លួន របស់លោក*ហ៊ុន សែន* ដែលជានាយករដ្ឋមន្ត្រីទី២នាសម័យនោះ ។

ដោយសារការបញ្ចប់ការស៊ើបអង្កេត មុនកាលកំណត់របស់ FBI ការិយាល័យស៊ើបអង្កេតនេះ បានប្រមូលភស្តុតាង មិនគ្រប់គ្រាន់សំរាប់ការកាត់ទោសហើយថ្វីបើមានការមក ពិនិត្យរយៈពេលខ្លីរបស់ FBI នៅឆ្នាំក្រោយៗជាបន្តបន្ទាប់ក៏ដោយ ក៏សំណុំរឿងនេះមិនមានការរីកចំរើនទៅមុខដែរហើយមិនត្រូវបានដោះស្រាយទេនៅក្រោយរយៈពេល១២ឆ្នាំមកនេះ ។ គ្មាននរណាម្នាក់ ត្រូវបានកាត់ទោសទេទាំងនៅក្នុងប្រទេសកម្ពុជា ឬនៅអាមេរិក ចំពោះការវាយប្រហារដែលនៅក្នុងនោះជនដៃដល់ ដែលគេមិនស្គាល់ បានគប់គ្រាប់បែកដៃ M-33 ផលិតនៅអាមេរិកចំនួន៤គ្រាប់ចូលក្នុងក្រុមបាតុករអហិង្សាជិត២០០នាក់ នៅទល់មុខអ្វីដែលជាអគាររដ្ឋសភា នាសម័យនោះដែលស្ថិតនៅលើមហាវិថី សម្តេចសុធារស ។

នៅក្នុងថ្ងៃ វាយប្រហារនោះ លោក*សម រង្ស៊ី* ប្រធានគណបក្សប្រឆាំង ដែលជាមេដឹកនាំ ក្បួនដង្ហែរនោះ ក៏បានបន្ទោសភ្លាមៗលើលោក*ហ៊ុន សែន*ជានាយករដ្ឋមន្ត្រីទី២ នៅក្នុងរដ្ឋាភិបាលចម្រុះមួយជាមួយគណបក្សហ៊្វុនស៊ិនប៉ិចនាសម័យនោះ ។ លោក*ហ៊ុន សែន* បានអំពាវនាវ ឱ្យមានការចាប់ខ្លួនលោក*សម រង្ស៊ី* ដោយមានប្រសាសន៍ថា លោក*សម រង្ស៊ី* ប្រហែលជាអ្នកទទួលខុសត្រូវលើការវាយប្រហារ ដោយគ្រាប់បែកដៃទៅលើក្បួនដង្ហែរបស់ខ្លួនឯង ។

លោក*ហ៊ុន សែន* តែងតែបដិសេធដាច់អហង្ការ មិនទទួលខុសត្រូវលើការវាយប្រហារនោះទេ ។ លោកនាយករដ្ឋមន្ត្រី ក៏បានសំរេចនូវកិច្ចព្រមព្រៀងមួយ កាលពីឆ្នាំ២០០៦ជាមួយលោក *សម រង្ស៊ី* ផងដែរ ដែលនៅក្នុងនោះលោក*សម រង្ស៊ី* នឹងបញ្ឈប់ជាចំហ នូវការចោទប្រកាន់ទៅលោកនាយករដ្ឋមន្ត្រី អំពីការទទួលខុសត្រូវលើការវាយប្រហារនោះ ។

ក្រុមមន្ត្រីនគរបាល មកពីគណបក្សហ៊្វុនស៊ិនប៉ិច ដែលក្នុងពេលនោះមានការគ្រប់គ្រងរួមគ្នា ជាមួយគណបក្សប្រជាជនកាលពីថ្ងៃទី៩ មេសា ១៩៩៧ បានអញ្ជើញជាផ្លូវការឱ្យ FBI ផ្តល់វិចិត្រករផ្នែកគំនូរព្រៀង ឬក៏អ្នកឯកទេសផ្នែកស្រាវជ្រាវព័ត៌មាន (ជាទេពកោសល្យដ៏សំខាន់ នៅក្នុងរង្វង់ FBI) ឱ្យជួយការស៊ើបអង្កេតរួមគ្នារបស់នគរបាលកម្ពុជា នៃគណបក្សប្រជាជនកម្ពុជានិងគណបក្សហ៊្វុនស៊ិនប៉ិចនៅក្នុងការកំណត់អត្តសញ្ញាណ ជនសង្ស័យនៅក្នុងការវាយប្រហារនោះ ។

កាលពីថ្ងៃទី២ ខែមេសា ឆ្នាំ១៩៩៧ FBI បានបើកការស៊ើបអង្កេតជាផ្លូវការរបស់ខ្លួន រួចទៅហើយលើកការវាយប្រហារដោយគ្រាប់បែកដៃនោះ ដោយសារតែរបួស លោក*រ៉ុន អាប់នី* ជាប្រធានប្រចាំប្រទេសកម្ពុជានៃវិទ្យាស្ថានសាធារណៈរដ្ឋអន្តរជាតិ ដែលបានរបួស ត្រូវអំបែងគ្រាប់ចំត្រគៀកដោយសារការវាយប្រហារ ដោយគ្រាប់បែកដៃនាសម័យនោះ ។

កាលពីថ្ងៃទី៤ មេសា ១៩៩៧ ផ្នែកភេរវកម្ម និងបទឧក្រិដ្ឋហិង្សា ដែលស្ថិតនៅ ក្នុងក្រសួងយុត្តិធម៌អាមេរិក ជាទីភ្នាក់ងាររដ្ឋាភិបាលដែលគ្រប់គ្រង FBI និងចាត់ចែងរឿងក្តីរបស់ខ្លួន បានចេញការសំរេច ដោយផ្តល់យុត្តាធិការដល់ FBI ឱ្យធ្វើការស៊ើបអង្កេតករណីនេះក្រោមច្បាប់សហព័ន្ធ របស់អាមេរិក ដែលហាមឃាត់ការប្រើប្រាស់អំពើហិង្សាដែលបណ្តាលឱ្យស្លាប់ លើជនជាតិអាមេរិក ក្នុងបណ្តាប្រទេសបរទេស ។

ការកាត់ទោសនានា ក្រោមច្បាប់នេះ អាចប្រព្រឹត្តទៅបានតែនៅក្នុងករណី មានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាមេរិក ឬក៏មន្ត្រីជាន់ខ្ពស់បំផុតទី២ នៅក្រសួងយុត្តិធម៌ ដែលទទួលខុសត្រូវលើការកាត់ទោសពីបទព្រហ្មទណ្ឌប៉ុណ្ណោះ ។

នៅមុនម៉ោង ៧យប់ នាថ្ងៃទី១០ ខែមេសាបន្តិច នៅក្នុងទីក្រុងវ៉ាស៊ីនតុន ការិយាល័យ របស់លោក *ហ្វ្រីសហ្វ្រី* ជាប្រធាន FBI នាសម័យនោះ បានសរសេរសំណើផ្ញើជូនផ្នែកប្រឆាំងភេរវកម្មនៃក្រសួងការបរទេសអាមេរិក ដើម្បីស្នើឱ្យមាន "*ការអនុញ្ញាត ចូលប្រទេស*" ឬការអនុញ្ញាត អោយធ្វើការនៅក្នុងប្រទេសកម្ពុជា សំរាប់អ្នកតំណាងFBI មួយរូបដែលនឹងមកដល់កម្ពុជា នៅថ្ងៃទី១៧ ខែមេសា ។

យោងតាមរបាយការណ៍ បើកចំហ ឆ្នាំ១៩៩៨ របស់ FBI ផ្ញើជូនគណៈកម្មការ ព្រឹទ្ធសភាអាមេរិក ទទួលបន្ទុកទំនាក់ទំនង ការបរទេសបានអោយដឹងថា នៅក្នុងឆ្នាំ១៩៩៨ ក្រុមអ្នកតំណាង របស់ FBI បានធ្វើការសម្ភាសន៍ ចំនួន៥៦លើក ជាមួយសាក្សីនិងប្រភពផ្សេងៗ ដោយ២៩លើក ជាមួយគណៈកម្មការនគរបាលរួមគ្នារវាង FBI និងកម្ពុជា ៦លើកជាមួយតែនគរបាល របស់គណបក្សហ៊្វុនស៊ិនប៉ិច ដែលមានវត្តមាន និង២៤លើក ជាលក្ខណៈឯកជន ជាមួយបុគ្គលិកស្ថានទូតអាមេរិក ដែលមានវត្តមានប៉ុណ្ណោះ ។

របាយការណ៍បើកចំហនេះដែលតម្រូវអោយ FBI បញ្ចេញតាមច្បាប់នោះមានខ្លឹមសារថាការបកស្រាយត្រូវបានធ្វើឡើងដោយបុគ្គលិករបស់ស្ថានទូតអាមេរិក នៅក្នុងបទសម្ភាសន៍ ចំនួន២៤លើក និងដោយលោក*សម រង្ស៊ី* ចំនួន៧លើក ។ FBI បានកំណត់ អត្តសញ្ញាណជនសង្ស័យ៣នាក់ ដែលត្រូវបានបង្ហាញឱ្យឃើញ នៅក្នុងរូបគំនូរព្រាង ដែលបានចុះផ្សាយនៅក្នុងសារព័ត៌មានកម្ពុជា កាលពីចុងខែឧសភា ឆ្នាំ១៩៩៧ ។

យោងតាមឯកសារនានា របស់ FBI និងក្រុមអ្នកយកព័ត៌មាន ដែលបានផ្សាយ ការវាយប្រហារ ដោយគ្រាប់បែកដៃនោះ បានឱ្យដឹងថា សាក្សីនៅកន្លែងកើតហេតុ បាននិយាយនៅពេលនោះថា នគរបាលមួយក្រុមតូចខុសពីធម្មតានៅកន្លែងប្រឆាំងតវ៉ា អហិង្សានោះ បានដកចេញភ្លាមៗ មុនពេលមានការផ្ទុះក្នុងក្រុមអ្នកប្រឆាំង តវ៉ា ក្នុងរយៈពេល១៥វិនាទី នៅម៉ោង ៨ និង២៥នាទីព្រឹក ។

សំខាន់ជាងនេះ ទៅទៀតនោះ ឯកសាររបស់ FBI កត់សំគាល់ថាក្រុមទាហាន (ដែលគេកំណត់អត្តសញ្ញាណថា ជាសមាជិក អង្គភាពអង្គរក្សរបស់លោក*ហ៊ុន សែន*) ដែល១៥នាក់ ក្នុងចំណោមពួកគេត្រូវបានដាក់ពង្រាយ ដោយគ្មានការពន្យល់បកស្រាយ នៅក្រោយក្បួនដង្ហែនោះត្រូវបានគេឃើញថាអនុញ្ញាត ឱ្យជនដៃដល់មួយចំនួនក្នុងចំណោមជនដៃដល់ ដែលគេចោទឡើង ឆ្លងកាត់ជួរសន្តិសុខរបស់ពួកគេ ក្រោយពីការផ្ទុះនោះ ហើយបានគេចខ្លួន ទៅកាន់ខ្លោងទ្វារវត្តបទុម ដែលស្ថិតនៅលើផ្លូវលេខ៧ ក្រោយសួនច្បារ ។

បន្ទាប់ពីការជួបប្រទះ នូវអ្វីដែលលោក *នីកូលែតទី* បានចាត់ទុកក្នុងរបាយការណ៍ ស៊ើបអង្កេតសង្ខេប ថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៩៧ ដែលត្រូវបានប្រកាសជាសាធារណៈថ្មីៗនេះថា ជា"*សកម្មភាពចេតនា បំភ័ន្តនិងយឺតយ៉ាវ*" របស់នគរបាលកម្ពុជានោះ FBI បានចាប់ផ្តើមស៊ើបអង្កេត ដោយមិនឱ្យពួកគេដឹងឡើយ ។

យោងតាមរបាយការណ៍សង្ខេបដែលត្រូវបានបញ្ជូនទៅឱ្យកងសន្តិសុខជាតិរបស់ FBI តាមរយៈការិយាល័យអនុវត្តច្បាប់ FBI នៅស្ថានទូតអាមេរិកប្រចាំទីក្រុងបាងកក លោក*នីកូលែតទី* បានជូនដំណឹង ដល់ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំប្រទេសកម្ពុជា នៅពេលនោះ គឺលោក *ខេណិត ខ្វីន* នៅឯកិច្ចប្រជុំ កាលពីថ្ងៃទី២ ឧសភាឆ្នាំ១៩៩៧ថា ដោយមិនមានការដឹងពីអាជ្ញាធរកម្ពុជាលោកបានបង្កើតប្រភពសម្ងាត់ចំនួន៣ ដែលបានផ្តល់នូវរូបថត និងរូបភាពវីដេអូរបស់នគរបាលទាំងអស់ អំពីការវាយប្រហារកាលពីឆ្នាំ១៩៩៧និងមានសាក្សី៤នាក់ ។

នៅក្នុងសំណៅ នៃសារ របស់ FBI ចេញឱ្យThe Cambodia Daily ឈ្មោះរបស់បុរស ទាំង២ នាក់ត្រូវបានកត់ត្រាទុក ដោយផ្នែកគ្រប់គ្រងឯកសាររបស់FBI ។ ទោះជាយ៉ាងណា របាយការណ៍ចំហរបស់ FBI នៅឆ្នាំ១៩៩៨ជូនទៅសមាជិកសភាអាមេរិក បានលើកឡើងថា លោក*ខ្វីន* និងភ្នាក់ងារស៊ើបអង្កេតរឿងក្តីនេះ បានស្ថិតនៅឯកិច្ចប្រជុំ ។ លោក*នីកូលែតទី* គឺជាភ្នាក់ងារស៊ើបអង្កេតរឿងក្តីនេះ ។

យោងតាមរបាយការណ៍សង្ខេប ថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៩៧ ដែលត្រូវបានបញ្ជូនមួយថ្ងៃបន្ទាប់ពីការធ្វើសម្ភាសន៍ទាំងនោះ បានឱ្យដឹងថា លោក*នីកូលែតទី* បានប្រាប់លោក*ខ្វីន* ថា "*ការសាកសួរប្រភព និងសាក្សីទាំងនេះត្រូវបានធ្វើឡើង នៅម៉ោងខុសៗគ្នា នៅក្នុងបន្ទប់សណ្ឋាគារជួល ដែលនៅដាច់ពីគេ ដោយមិនមានការដឹងពីស្នងការនគរបាលកម្ពុជាឡើយ*" ។

យោងតាមឯកសាររបស់ FBI ដែលកាសែត The Cambodia Daily បានទទួលបានឱ្យដឹងថានៅក្នុងចម្លើយរបស់សាក្សី ដែលត្រូវបានដកស្រង់ នៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី១៣ ឧសភា ពីការិយាល័យ FBI នៅក្នុងក្រុងហូណូលូលូ ផ្ញើទៅទីស្នាក់ការ កណ្តាលរបស់ការិយាល័យ FBI នៅក្នុងទីក្រុងវ៉ាស៊ីនតុន និងផ្ញើទៅ ការិយាល័យរបស់ខ្លួន នៅឯស្ថានទូត អាមេរិកប្រចាំទីក្រុងបាងកកថាបុរសម្នាក់បានអះអាងក្នុងបទសម្ភាសន៍ថា បានឃើញជនល្មើសភ្លាមៗនៅបន្ទាប់ពីការវាយប្រហារនោះចេញតាមក្រោយវត្តបទុម ហើយចូលទៅបន្ទាយយោធា នៅក្បែរនោះ

**តទៅទំព័រទី៣ ន**

**តមកពីទំព័រទី១ ក**

**ដីធ្លី និងអ្នកដែលមានដីធ្លីមួយគ្រួសារទំហំតូចជាង១ហិកតាកាន់តែមានចំនួនច្រើនជាងនេះទៅទៀត។ នេះគឺដូចជាវិធានការដែលសម្រេចឡើងដោយអាជ្ញាធរនៅខេត្តកំពង់ធំ ក៏ដូចជាខេត្តឧត្តរមានជ័យ ដែលបានបញ្ចេញនូវរបស់ដែលហៅថាគោលនយោបាយរបស់រដ្ឋាភិបាលបែងចែកដីឱ្យប្រជាកសិករមួយគ្រួសារទំហំតែ១ហិកតាជាដីកសិកម្ម បន្ថែមពីលើដីភូមិទំហំ២០ម៉ែត្រ គុណនឹង៤០ម៉ែត្រសម្រាប់ទីលំនៅ ដើម្បីព្យាយាមបញ្ឈប់ការតវ៉ារបស់ប្រជាកសិករទាំងនោះក្នុងជម្លោះដីធ្លីតទល់នឹងក្រុមហ៊ុនឯកជនដែលមានកម្លាំងរដ្ឋាភិបាលនៅពីក្រោយខ្នង។**

**នៅខេត្តកំពង់ធំ បញ្ហាជម្លោះដីធ្លីរវាងសមាគមយោធិនពិការ និងអតីតយុទ្ធជនកាត់រំសាយ រួមជាមួយប្រជារាស្ត្រក្រីក្រជាង១៥០០គ្រួសារក្នុងភូមិបន្ទាយរងៀង ឃុំក្រយាស្រុកសន្ទុក អាជ្ញាធររដ្ឋាភិបាលថ្នាក់ខេត្តនិយាយអំពីការកំណត់គោលការណ៍ចែកដីឱ្យពួកគាត់តែមួយហិកតា ជាដីកសិកម្ម ដើម្បីជាថ្នូរនឹងការបណ្តេញពួកគាត់ចេញពីដីភូមិដែលពួកគាត់រស់នៅដោយស្របច្បាប់ តាមការអនុញ្ញាតិរបស់ក្រសួងមហាផ្ទៃ។ ហើយរួមជាមួយនឹងការអនុវត្តគោលនយោបាយក្នុងខេត្តឧត្តរមានជ័យ នៃកសិករដែលតវ៉ារឿងបញ្ហាដីធ្លីកសិកម្មដែរ គឺដីមួយហិតាសម្រាប់កសិករមួយគ្រួសារ មិនថាគ្រួសារមានសមាជិកប៉ុន្មាននាក់នោះ ជារបបមួយនៃជំរើសដំណោះស្រាយ និយាយពន្យល់បានអំពីផ្នត់គំនិតរបស់មេដឹកនាំកម្ពុជា។**

**ប៉ុន្តែដោយសារកសិករខ្មែរមួយគ្រួសារៗ មានមនុស្សជាមធ្យម៧នាក់នោះ ច្បាស់ណាស់ថា ដីកសិកម្មទំហំ១ហិកតា ពុំអាចធានាឱ្យពួកគាត់មានជីវភាពធូរធារដូចការអះអាងនៃរបស់ដែលហៅថា គោលនយោបាយចតុកោណនៃរដ្ឋាភិបាលអួតអំពីការកាត់បន្ថយភាពក្រីក្ររបស់ប្រជារាស្ត្រនោះទេ។ ហើយនោះគឺជាដំណើរនិន្នាការមួយដែលកំពុងរាលដាលទៅតំបន់ផ្សេងៗដោយបង្កើតជាមូលដ្ឋានកង្វល់ព្រួយរបស់ពលរដ្ឋទូទៅជាពិសេសនៅពេលដែលរដ្ឋាភិបាលកំពុងព្យាយាមជំរុញសេចក្តីព្រាងច្បាប់អសារនិករណ៍ដើម្បីដកហូតនូវដីធ្លីអចលនទ្រព្យទាំងដាំណាំទាំងឡាយរបស់ពលរដ្ឋ សូម្បីតែមានកម្មសិទ្ធិស្របច្បាប់ត្រឹមត្រូវទៅហើយនោះក្នុងឈ្មោះថា យកទៅប្រើប្រាស់ជាប្រយោជន៍សាធារណៈឬប្រយោជន៍ជាតិ។**

**ផ្អែកលើមតិលើកឡើងជាជំរើសកំណត់គោលនយោបាយរបស់ទីភ្នាក់ងារជំនួយអភិវឌ្ឍន៍អន្តរជាតិ ជាពិសេសធនាគារពិភពលោក ដែលបានធ្វើការតាមដាន និងសិក្សាយ៉ាងស៊ីជំរៅដល់អ្វីជាមូលដ្ឋានអាចឱ្យប្រជាកសិករខ្មែររស់នៅពឹងពាក់បាន និងមានដំណើរជីវភាពធូរធារឡើងនោះ កសិករខ្មែរមួយគ្រួសារត្រូវការនូវដីធ្លីកសិកម្មទំហំយ៉ាងតូច២ហិកតា។ គឺ២ហិកតាសម្រាប់កសិករខ្មែរ១គ្រួសារ ដែលជាមធ្យមមានសមាជិក៧រូបនោះ ហើយដែលនេះនៅត្រូវការនូវជំនួយឧបត្ថម្ភខាងការបណ្តុះបណ្តាលបច្ចេកវិទ្យា បណ្តុះស្មារតីទាក់ទងនឹងវិស័យដាំដុះផ្នែកកសិកម្មនានា សម្រាប់ធានាថា ប្រជារាស្ត្រខ្មែរជាកសិករមានមូលដ្ឋានរស់នៅនឹងធំ នោះទើបអាចធានាការដោះស្រាយជីវភាពឱ្យធូរធារឡើងបាន។**

**ប៉ុន្តែតើអាចទៅរួចឬទេ បើម្ចាស់ជំនួយសិក្សាឃើញថាប្រជាកសិករខ្មែរមួយគ្រួសារត្រូវការដីធ្លីកសិកម្មទំហំ២ហិកតា ឯរដ្ឋាភិបាលកាត់យកអស់មួយហិកតាទុកឱ្យប្រជាកសិករខ្មែរត្រឹមតែមួយហិកតា សូម្បីតែដឹងថា ដីកសិកម្មមួយហិកតានេះ ប្រជារាស្ត្រពិបាក កុំថាឡើយដល់តម្កើងជីវភាពឱ្យធូរធារ សូម្បីតែការធានាជីវភាពរស់ឱ្យសមរម្យល្មមគ្រប់គ្រាន់នោះ ? រឿងជីវភាពប្រជារាស្ត្រត្រូវលើកស្ទួយឱ្យធូរធារឡើង បើទោះបីជាមានការចែងនៅក្នុងកម្មវិធីនយោបាយនៃគណបក្សប្រជាជនកាន់អំណាចប្រើប្រាស់ពាក្យថា នយោបាយចតុកោណកាត់បន្ថយភាពក្រីក្ររបស់ប្រជាកសិករក៏ដោយក៏ការអនុវត្តជាក់ស្តែងកំណត់ដីឱ្យប្រជារាស្ត្រទំហំតែ១ហិកតា សម្រាប់មួយគ្រួសារមានគ្នាដល់ទៅ៦-៧នាក់នោះ ច្បាស់ណាស់ថា ពុំមានថ្ងៃណាប្រជាកសិករខ្មែរស្គាល់នូវជីវភាពធូរធារនោះទេ។ គឺជាស្ថានភាពដែលកំពុងកើតមានផ្ទួនគ្នានឹងការអនុវត្តគោលនយោបាយបែបនោះ ភ្ជាប់ផ្សំនឹងការប្រើអំណាចកម្លាំង ទាំងកម្លាំងប្រដាប់អាវុធបង្ខំដេញប្រជារាស្ត្រចេញពីដីធ្លី ផ្ទះសម្បែង ពីដីធ្លីកសិកម្ម។ នោះការផ្លាស់ទីលំនៅវិលវល់ចុះឡើងពុំមានលំនឹងជាមូលដ្ឋាន ដូចការកត់សម្គាល់របស់ធនាគារពិភពលោក និងម្ចាស់ជំនួយថា ធ្វើឱ្យប្រជារាស្ត្រមិនអាចមានជីវភាពធូរធារប្រសើរឡើងនោះទេ បើគេនៅតែអនុវត្តនយោបាយបណ្តេញប្រជារាស្ត្រឱ្យរុះរើផ្ទះសម្បែងពីតំបន់មួយ ទៅតំបន់មួយក្រោមលេសអភិវឌ្ឍន៍នោះ។**

**ការគួរឱ្យកត់សម្គាល់មួយទៀតនោះ គឺបើទោះបីជារដ្ឋាភិបាលនិយាយអំពីការជួយកសិករតាមគោលនយោបាយចតុកោណរបស់ខ្លួនក៏ដោយ ក៏បើពិនិត្យមើលការអនុវត្តគោលនយោបាយជាក់ស្តែងវិញ ពុំមែនប្រជារាស្ត្រនោះទេជាគោលដៅនៃការជួយជ្រោមជ្រែងជាអាទិភាពក្នុងសកម្មភាពរបស់រដ្ឋាភិបាល។ ផ្ទុយទៅវិញគឺក្រុមហ៊ុនឈ្មួញឯកជនក្នុងស្រុក ទាំងពីក្រៅប្រទេសរាប់ទាំងក្រុមហ៊ុនយួនឯណោះទៅវិញ ដែលជាបំណងដ៏សំខាន់ក្នុងការជួយជ្រោមជ្រែងរបស់រដ្ឋាភិបាល។ នោះមានបញ្ជាក់ដោយឧទាហរណ៍ជាក់ស្តែង ត្រង់ការដែលរដ្ឋាភិបាលនៃលោក ហ៊ុន សែន បានសន្យារកដីនៅ កម្ពុជាទំហំជាង១០ម៉ឺនហិកតាប្រគល់ឱ្យក្រុមហ៊ុនយួនក្រោមលេសថា អភិវឌ្ឍន៍ដំណាំចំការកៅស៊ូ។**

**គឺជាការអភិវឌ្ឍន៍មួយដែលមានអត្ថន័យយ៉ាងពិរោះហើយដែលផលរបស់វាគឺល្វីងជូរចត់សម្រាប់ប្រជារាស្ត្រ ពីព្រោះនោះគឺប្រជារាស្ត្រក្លាយទៅជាគោលដៅនៃការបង្ខំដេញលើករណីយោធិនពិការ និងអតីតយុទ្ធជន ព្រមទាំងប្រជារាស្ត្រខ្មែរជាង១ពាន់គ្រួសារនៅឃុំក្រយាង ស្រុកសន្ទុក ខេត្តកំពង់ធំ ដែលអាជ្ញាធររដ្ឋាភិបាលប្រើកម្លាំងប្រដាប់អាវុធរបស់ជាតិដេញពួកគាត់ឱ្យចេញពីដី ហើយយកទៅប្រគល់ឱ្យក្រុមហ៊ុនយួននោះ៕**